# ព្រះរាជក្រម

នស/រកម/០៧១០/០១៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**


លេខ..........
ថ្ងៃទី..../....ឆ្នាំ២០១០ ម៉ោង....
បញ្ជូនទៅ..........


- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងវិនិយោគក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :


ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ច្បាប់

ស្តីពី

# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងវិនិយោគក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងវិនិយោគក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ដែលបានចុះហត្ថលេខានៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃឡង់ដ៍ នាថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៩ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

ពរល.១០០៤.៦៤៩

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ: ៥៧១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

[illegible] កេន

# កិច្ចព្រមព្រៀងស្តីពីវិនិយោគនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី សហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិ អាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន

រដ្ឋាភិបាលនៃប្រ៊ុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ជារដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ("ហៅកាត់រួមគ្នាថា អាស៊ាន") ឬ ("រដ្ឋសមាជិកអាស៊ានទាំងអស់") ឬហៅកាត់ដាច់ដោយឡែកថា ("រដ្ឋសមាជិកអាស៊ាន") និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ("ចិន")

**ដោយរំលឹកឡើងវិញ** នូវកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ ("កិច្ចព្រមព្រៀងក្របខ័ណ្ឌ") រវាងអាស៊ាន និងចិន (ហៅរួមគ្នាថា "ភាគីទាំងអស់" ឬហៅដាច់ដោយឡែកថា រដ្ឋសមាជិកអាស៊ាន ឬចិន ជា "ភាគីមួយ" ដែលបានចុះហត្ថលេខាដោយប្រមុខរដ្ឋាភិបាល/រដ្ឋនៃរដ្ឋសមាជិកអាស៊ាន និងចិន នៅទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០២

**ដោយរំលឹកឡើងវិញជាបន្ថែម** នូវមាត្រា ៥ និងមាត្រា ៨ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ដើម្បីនឹងបង្កើតនូវតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន និងដើម្បីជំរុញការវិនិយោគ ព្រមទាំងបង្កើតរបបវិនិយោគសេរី សម្របសម្រួល តម្លាភាព និងប្រកួតប្រជែង ភាគីទាំងអស់ឯកភាពគ្នាដើម្បីចរចា និងបូកសរុបបញ្ចប់កិច្ចព្រមព្រៀងវិនិយោគ អោយបានលឿនតាមដែលអាចធ្វើបាន សំដៅធ្វើសេរីភាវូបនីយកម្ម ជាលំដាប់នូវរបបវិនិយោគ ពង្រឹងសហប្រតិបត្តិការក្នុងការវិនិយោគ សម្របសម្រួលការវិនិយោគ និងកែលំអតម្លាភាពនៃវិធាន និងបទបញ្ញត្តិវិនិយោគ ព្រមទាំង ផ្តល់ការការពារចំពោះការវិនិយោគ

**ដោយកត់សំគាល់ថា** កិច្ចព្រមព្រៀងក្របខ័ណ្ឌទទួលស្គាល់នូវដំណាក់កាល និងល្បឿនខុសគ្នានៃការអភិវឌ្ឍ ក្នុងចំណោមភាគីទាំងអស់ និងតម្រូវការប្រព្រឹត្តិកម្មពិសេស និងដោយឡែក ព្រមទាំងភាពទន់ភ្លន់សំរាប់រដ្ឋជាសមាជិកថ្មីរបស់អាស៊ាន ដែលមាន កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម

**ដោយបញ្ជាក់អះអាងឡើងវិញ** នូវការប្ដេជ្ញារបស់ភាគីទាំងអស់ដើម្បីបង្កើតឡើងនូវតំបន់ពាណិជ្ជកម្មសេរី អាស៊ាន-ចិន ក្នុងកាលបរិច្ឆេទជាក់លាក់មួយ ដោយអនុញ្ញាតិអោយមានភាពទន់ភ្លន់ចំពោះភាគីទាំងអស់ ដើម្បីដោះស្រាយវិស័យ វេទយិតភាពរបស់ពួកគេ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ ក្នុងការសម្រេចអោយបាននូវគោលដៅកំណើន និងអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចិរភាព ផ្អែកលើមូលដ្ឋាននៃសមភាព និងអត្ថប្រយោជន៍ទៅវិញទៅមក ដើម្បីសម្រេចបាននូវលទ្ធផលឈ្នះ-ឈ្នះ

**ដោយបញ្ជាក់អះអាងឡើងវិញជាបន្ថែម** នូវសិទ្ធិ កាតព្វកិច្ច និងការសន្យារបស់ភាគីនីមួយៗ ក្រោមអង្គការពាណិជ្ជកម្មពិភពលោក ("WTO") និងកិច្ចព្រមព្រៀង ព្រមទាំងការរៀបចំពហុភាគី តំបន់ និងទ្វេភាគីផ្សេងទៀត

**បានឯកភាពគ្នា** ដូចខាងក្រោម :

## មាត្រា ១

## និយមន័យ

១. សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ :

(ក) "AEM" មានន័យថា រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន

(ខ) **"រូបិយប័ណ្ណអាចប្រើប្រាស់ដោយសេរី"** មានន័យថា រូបិយប័ណ្ណណាមួយដែលត្រូវបានជ្រើសមកប្រើ ដូចបានកំណត់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ ("IMF") ក្រោមមាត្រានៃកិច្ចព្រមព្រៀងរបស់ IMF និងវិសោធនកម្មនានាដែលមាននៅក្នុងកិច្ចព្រមព្រៀងនេះ ។

(គ) "GATS" មានន័យថា កិច្ចព្រមព្រៀងទូទៅស្ដីពីពាណិជ្ជកម្មក្នុងវិស័យសេវាកម្ម ក្នុងឧបសម្ព័ន្ធ ១ B នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក

(ឃ) **"ការវិនិយោគ"** មានន័យថា ទ្រព្យសម្បត្តិគ្រប់ប្រភេទ ដែលវិនិយោគដោយអ្នកវិនិយោគរបស់ ភាគីមួយ អនុលោមតាមច្បាប់ពាក់ព័ន្ធ បទប្បញ្ញត្តិ និងគោលនយោបាយ[១] នៃភាគីមួយទៀត នៅក្នុងដែនដីនៃភាគីក្រោយនេះ ដោយរាប់បញ្ចូលប៉ុន្តែមិនកំណត់ចំពោះទ្រព្យសម្បត្តិដូចខាងក្រោមនេះទេ :

---

[១] ដើម្បីអោយកាន់តែប្រាកដ គោលនយោបាយនានាត្រូវយោងដល់ គោលនយោបាយដែលប៉ះពាល់ដល់ការវិនិយោគ ដែលត្រូវបានទទួលការឯកភាព ឬប្រកាសដោយរដ្ឋាភិបាលនៃភាគីមួយ និងផ្សព្វផ្សាយជាសាធារណៈក្នុងទំរង់ជាលាយ លក្ខណ៍អក្សរ ។

(i) ចលនទ្រព្យ និងអចលនទ្រព្យ និងសិទ្ធិលើទ្រព្យសម្បត្តិដទៃទៀត ដូចជា ទ្រព្យដាក់បញ្ចាំ ប្រាតិភោគបំណុល (វត្ថុដាក់ធានាបំណុល) ឬប្រាក់សន្យាផ្តល់អោយ

(ii) ភាគហ៊ុន ហ៊ុន និងប័ណ្ណបំណុលនៃនីតិបុគ្គល ឬផលប្រយោជន៍នៅក្នុងទ្រព្យសម្បត្តិនៃនីតិបុគ្គលនោះ

(iii) កម្មសិទ្ធិបញ្ញា រាប់បញ្ចូលទាំងសិទ្ធិទាក់ទងនឹងសិទ្ធិមិនអោយចំលង ប្រកាសនីយប័ត្រ តក្កកម្ម ម៉ូតដែលមានប្រយោជន៍ គំនូរឧស្សាហកម្ម ពាណិជ្ជសញ្ញា និងសញ្ញាសេវា ការបង្ហាញភូមិសាស្ត្រ គំនូសប្លង់នៃបង្គុំចំរុះ (Intergrated Circuits) ពាណិជ្ជនាម ការសម្ងាត់ពាណិជ្ជកម្ម ដំណើរការបច្ចេកទេស ចំណេះធ្វើ និងសុច្ឆន្ទៈ

(iv) សម្បទានពាណិជ្ជកម្ម[២] ដែលផ្តល់ដោយច្បាប់ ឬក្រោមកិច្ចសន្យា រាប់បញ្ចូលទាំងសម្បទាន ដើម្បីស្រាវជ្រាវ ដាំដុះ ការធ្វើនិស្សារណកម្ម ឬធ្វើអាជីវកម្មធនធានធម្មជាតិ និង

(v) ការទាមទារសំណងជាប្រាក់ ឬជាការអនុវត្តកិច្ចសន្យា ដែលមានតម្លៃហិរញ្ញវត្ថុ ។

សំរាប់គោលបំណងរបស់និយមន័យនៃការវិនិយោគនៅក្នុងអនុកថាខ័ណ្ឌនេះ ផលនៃការវិនិយោគ គប្បីចាត់ទុកថា ជាទឹកប្រាក់វិនិយោគ ហើយរាល់ការកែប្រែទំរង់ដែលទ្រព្យសម្បត្តិត្រូវបានវិនិយោគ ឬត្រូវបានវិនិយោគឡើងវិញ មិនប៉ះពាល់ដល់ចរិតនៃការវិនិយោគឡើយ

(ង) **"អ្នកវិនិយោគរបស់ភាគីមួយ"** មានន័យថា រូបវន្តបុគ្គលនៃភាគីមួយ ឬនីតិបុគ្គលនៃភាគីមួយ ដែលកំពុងធ្វើ[៣] ឬបានធ្វើការវិនិយោគក្នុងដែនដីនៃភាគីដទៃទៀត

(ច) **"នីតិបុគ្គលនៃភាគីមួយ"** មានន័យថា នីតិបុគ្គលណាមួយ ដែលបានបង្កើតឡើងត្រឹមត្រូវតាមច្បាប់ ឬរៀបចំឡើងតាមបែបផ្សេងទៀតត្រឹមត្រូវតាមច្បាប់ ជាធរមានរបស់ភាគីមួយ ទោះបីជាដើម្បីស្វែងរកចំណេញ ឬផ្សេងពីនេះក្តី និងទោះបីជាកម្មសិទ្ធិរបស់ឯកជន

---

[២] សម្បទានពាណិជ្ជកម្ម រាប់បញ្ចូលទាំងសិទ្ធិលើកិច្ចសន្យា ដូចជា សិទ្ធិនៅក្រោមកិច្ចសន្យាទទួលយកសមិទ្ធិផល កិច្ចសន្យាសាងសង់ ឬកិច្ចសន្យាគ្រប់គ្រង កិច្ចសន្យាផលិតកម្ម ឬកិច្ចសន្យាចែករំលែកប្រាក់ចំណូល សម្បទាន ឬកិច្ចសន្យាស្រដៀងគ្នាដទៃទៀត ហើយអាចរាប់បញ្ចូលទាំងមូលនិធិនៃការវិនិយោគ សំរាប់គំរោងនានា ដូចជា គម្រោង "សាងសង់-ប្រតិបត្តិការ-ផ្ទេរ" និងសាងសង់-ប្រតិបត្តិការ និងធ្វើជាម្ចាស់" (BOO) ។

[៣] ដើម្បីអោយកាន់តែប្រាកដ ឃ្លា "កំពុងធ្វើ" ត្រូវយោងដល់ចំពោះតែមាត្រា៩ (ប្រព្រឹត្តិកម្មជាតិអនុគ្រោះបំផុត) និងមាត្រា ១០ (ការផ្ទេរ និងការបង្វិលប្រាក់ចំណេញ) ។

ឬកម្មសិទ្ធិរបស់រដ្ឋក្តី និងពាក់ព័ន្ធក្នុងប្រតិបត្តិការធុរកិច្ច សំខាន់ៗក្នុងដែនដីនៃភាគីនោះ រាប់បញ្ចូលទាំង សាជីវកម្ម ឯកាធិកម្ម សហកម្មសិទ្ធិ សម្ព័ន្ធអាជីវកម្ម ឯកកម្មសិទ្ធិ ឬសមាគម

(ឆ) **"វិធានការ"** មានន័យថា ច្បាប់ បទប្បញ្ញត្តិ វិធាន នីតិវិធី ឬសេចក្តីសំរេច ឬសកម្មភាព រដ្ឋបាលណាមួយនៃការអនុវត្តជាទូទៅ ដែលប៉ះពាល់ដល់អ្នកវិនិយោគ និង/ឬការវិនិយោគ ដែលធ្វើឡើងដោយភាគីមួយរាប់បញ្ចូលទាំងវិធានការរបស់ :

(i) រដ្ឋាភិបាល និងអាជ្ញាធរថ្នាក់កណ្តាល ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋាន

(ii) ស្ថាប័នមិនមែនរដ្ឋាភិបាល ក្នុងការអនុវត្តសិទ្ធិអំណាច ដែលត្រូវបានធ្វើប្រតិភូកម្ម ដោយរដ្ឋាភិបាល និងអាជ្ញាធរថ្នាក់កណ្តាល ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋាន

(ជ) **"MOFCOM"** មានន័យថា ក្រសួងពាណិជ្ជកម្ម នៃសាធារណរដ្ឋប្រជាមានិតចិន

(ឈ) **"រូបវ័ន្តបុគ្គល"** នៃភាគីមួយ មានន័យថា រូបវ័ន្តបុគ្គលណាមួយ ដែលមានសញ្ជាតិ ឬទទួលបាននូវសញ្ជាតិ ឬសិទ្ធិ នៃការស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងទឹកដីនៃភាគីមួយ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ[៤] របស់ភាគីនោះ ។

(ញ) **"ផលនៃការវិនិយោគ"** មានន័យថា ចំនួនទឹកប្រាក់ដែលរកបានដោយការវិនិយោគ ឬពីការវិនិយោគ ជាពិសេស ទោះបី មិនរាប់បញ្ចូលនូវប្រាក់ចំណេញ ការប្រាក់ ចំណេញជាមូលធន ភាគលាភ កំរៃសួយសារ ឬកំរៃផ្សេងៗក៏ដោយ

(ដ) **"SEOM"** មានន័យថា កិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន

---

[៤] សំរាប់ករណីប្រទេសឥណ្ឌូនេស៊ី ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម ដែលមិនផ្តល់សិទ្ធិនៃការស្នាក់នៅជាអចិន្ត្រៃយ៍ ចំពោះជនបរទេស ឬពុំផ្តល់អោយអ្នកស្នាក់នៅជាអចិន្ត្រៃយ៍របស់ខ្លួននូវផលប្រយោជន៍ដូចគ្នា ដូចនឹងជនជាតិ ឬពលរដ្ឋរបស់ខ្លួន ប្រទេសទាំងនេះពុំត្រូវជាប់កាតព្វកិច្ចផ្លូវច្បាប់ ដើម្បីផ្តល់ផលប្រយោជន៍នៃកិច្ចព្រមព្រៀងនេះទៅអោយអ្នកស្នាក់នៅជាអចិន្ត្រៃយ៍នៃភាគីណាមួយនៃភាគីដទៃទៀត ឬទាមទារអត្ថប្រយោជន៍ដូចពោលខាងលើសំរាប់អ្នកស្នាក់នៅជាអចិន្ត្រៃយ៍របស់ខ្លួនឡើយ ប្រសិនជាអាចអនុវត្តបានពីភាគីណាមួយនៃភាគីដទៃទៀត ។

សំរាប់ករណីប្រទេសចិន ប្រសិនបើមានបដិការពីភាគីដទៃទៀតនោះ រហូតដល់ពេលចិន អនុម័តច្បាប់ក្នុងស្រុករបស់ខ្លួន ស្តីពីប្រព្រឹត្តិកម្មនៃអ្នកស្នាក់នៅជាអចិន្ត្រៃយ៍នៃជនបរទេស អ្នកស្នាក់នៅជាអចិន្ត្រៃយ៍នៃភាគីដទៃទៀត ត្រូវបានទទួលនូវប្រព្រឹត្តិកម្មមិនតិចជាងអ្វីដែលខ្លួនផ្តល់ អោយចំពោះប្រទេសទីបី ក្នុងកាលៈទេសៈដូចគ្នា ប្រសិនបើអ្នកស្នាក់នៅជាអចិន្ត្រៃយ៍ទាំងនោះ បោះបង់សិទ្ធិរបស់ខ្លួនដែលអាចកើត ចេញពីបញ្ញត្តិនៃការដោះស្រាយវិវាទ ក្រោមកិច្ចព្រមព្រៀងវិនិយោគដទៃទៀត ឬការរៀបចំ ដែលបានធ្វើឡើងរវាងចិន និងប្រទេស ទីបី ។

(ឋ) **"កិច្ចព្រមព្រៀង WTO"** មានន័យថា កិច្ចព្រមព្រៀងម៉ារ៉ាកេស (Marrakesh) ធ្វើនៅទីក្រុងម៉ារ៉ាកេស ប្រទេសម៉ូរ៉ុកកូ នាថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៤ ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដូចដែលអាចត្រូវបានធ្វើវិសោធនកម្ម ។

២. និយមន័យនៃពាក្យស័ព្ទនីមួយៗក្នុងចំណោមពាក្យស័ព្ទខាងលើ ត្រូវអនុវត្ត លើកលែងតែបរិបទតម្រូវផ្សេងពីនេះ ឬនៅពេលដែលភាគីមួយបានអោយនិយមន័យជាក់លាក់ទៅលើពាក្យសព្ទណាមួយក្នុងចំណោមពាក្យស័ព្ទខាងលើសំរាប់ការអនុវត្តចំពោះការប្តេជ្ញា ឬការបំរុងទុករបស់ខ្លួន ។

៣. ក្នុងកិច្ចព្រមព្រៀងនេះ គ្រប់ពាក្យទាំងអស់ដែលត្រូវបានប្រើជាឯកវចនៈ ត្រូវរាប់បញ្ចូលទាំងពហុវចនៈ ហើយរាល់ពាក្យទាំងអស់ដែលត្រូវបានប្រើប្រាស់ជាពហុវចនៈ ក៏ត្រូវរាប់បញ្ចូលទាំងឯកវចនៈផងដែរ លើកលែង តែបរិបទតម្រូវផ្សេងពីនេះ ។

## មាត្រា ២

## គោលបំណង

គោលបំណងនៃកិច្ចព្រមព្រៀងនេះ គឺដើម្បីជំរុញលំហូរនៃការវិនិយោគ និងដើម្បីបង្កើតរបបវិនិយោគមួយដែលសេរី សម្របសម្រួល តម្លាភាព និងមានភាពប្រកួតប្រជែងក្នុងអាស៊ាន និងចិន តាមរយៈខ្លឹមសារដូចខាងក្រោម :

(ក) ធ្វើសេរីភាវូបនីយកម្មឈានឡើងជាលំដាប់ នៃរបបវិនិយោគរបស់អាស៊ាន និងចិន

(ខ) បង្កើតលក្ខខណ្ឌអនុគ្រោះសំរាប់ការវិនិយោគដោយអ្នកវិនិយោគនៃភាគីមួយក្នុងដែនដីនៃភាគីផ្សេងមួយទៀត

(គ) ជំរុញកិច្ចសហប្រតិបត្តិការរវាងភាគីមួយ និងអ្នកវិនិយោគ ដែលមានការវិនិយោគនៅក្នុងដែនដីនៃភាគីនោះ ផ្អែកលើគោលការណ៍ផលប្រយោជន៍ទៅវិញទៅមក

(ឃ) លើកទឹកចិត្ត និងជំរុញលំហូរវិនិយោគក្នុងចំណោមភាគីទាំងអស់ និងសហប្រតិបត្តិការក្នុងចំណោមភាគីទាំងអស់ លើរាល់បញ្ហាទាក់ទងនឹងការវិនិយោគ

(ង) កែលំអតម្លាភាពនៃវិធានវិនិយោគប្រកបដោយភាពអនុគ្រោះចំពោះការបង្កើនលំហូរនៃការវិនិយោគក្នុងចំណោមភាគីទាំងអស់ និង

(ច) ផ្តល់ការការពារចំពោះការវិនិយោគនៅក្នុងអាស៊ាន និងចិន ។

## មាត្រា ៣

## វិសាលភាពនៃការអនុវត្ត

១. កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះវិធានការដែលបានប្រកាន់យក ឬរក្សាទុកដោយភាគីមួយ ទាក់ទងនឹង :

(ក) អ្នកវិនិយោគនៃភាគីណាមួយផ្សេងទៀត និង

(ខ) ការវិនិយោគនៃអ្នកវិនិយោគរបស់ភាគីណាមួយផ្សេងទៀត ក្នុងដែនដីរបស់ខ្លួន ដែល:

(i) ទាក់ទងនឹងប្រទេសចិន គឺជាដែនដីគយទាំងមូល អនុលោមតាមនិយមន័យរបស់ WTO ក្នុងពេលដែលចិនចូលជាសមាជិក WTO នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០១ ។ សំរាប់ គោលបំណងនេះ ចំពោះ ចិន "ដែនដី" ក្នុងកិច្ចព្រមព្រៀងនេះ យោងទៅលើដែនដីគយនៃចិន និង

(ii) ទាក់ទងនឹងរដ្ឋជាសមាជិកអាស៊ានទាំងអស់ គឺជាដែនដីរៀង១ខ្លួនរបស់រដ្ឋជាសមាជិក

២. លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងកិច្ចព្រមព្រៀងនេះ កិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះរាល់ការវិនិយោគទាំងអស់ ដែលបានធ្វើឡើងដោយអ្នកវិនិយោគនៃភាគីមួយក្នុងដែនដីនៃភាគីមួយផ្សេងទៀត ទោះបីជាធ្វើឡើងនៅមុន ឬក្រោយការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះក៏ដោយ ។ ដើម្បីអោយកាន់តែប្រាកដ បញ្ញត្តិទាំងអស់នៃកិច្ចព្រមព្រៀងនេះ ពុំភ្ជាប់កាតព្វកិច្ចនៃភាគីណាមួយ ទាក់ទងនឹងសកម្មភាព ឬហេតុការណ៍ណាមួយដែលកើតឡើង ឬស្ថានភាពណាមួយ ដែលលែងមានអត្ថិភាព នៅមុនកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ។

៣. សំរាប់ករណីប្រទេសថៃ កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះតែក្នុងករណីដែលការវិនិយោគដោយអ្នកវិនិយោគណាម្នាក់នៃភាគីមួយផ្សេងទៀតក្នុងដែនដីប្រទេសថៃត្រូវបានអនុញ្ញាត និងយល់ព្រមដោយជាក់លាក់ជាលាយលក្ខណ៍អក្សរសំរាប់ការការពារដោយអាជ្ញាធរមានសមត្ថកិច្ច[៥] របស់ខ្លួន អនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយក្នុងស្រុកប៉ុណ្ណោះ ។

---

[៥] ឈ្មោះ និងអាស័យដ្ឋានទំនាក់ទំនងលំអិតនៃអាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសំរាប់ផ្តល់ការយល់ព្រមទាំងនោះ នឹងត្រូវជូនដំណឹងទៅភាគីដទៃទៀតទាំងអស់តាមរយៈលេខាធិការដ្ឋានអាស៊ាន ។

៤. កិច្ចព្រមព្រៀងនេះ មិនត្រូវអនុវត្តចំពោះ :

(ក) វិធានការពន្ធដារណាមួយ ។ អនុកថាខ័ណ្ឌនេះ នឹងមិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាំងអស់ ទាក់ទងទៅនឹងវិធានការពន្ធដារឡើយ :

(i) នៅពេលដែលសិទ្ធិ ឬកាតព្វកិច្ចត្រូវបានផ្តល់អោយ ឬកំណត់ក្រោមកិច្ចព្រមព្រៀងរបស់ WTO ដែរនោះ

(ii) នៅក្រោមមាត្រា ៨ (ការដកហូត) និងមាត្រា ១០ (ការផ្ទេរ និងការបង្វិលប្រាក់ចំណេញ)

(iii) នៅក្រោមមាត្រា ១៤ (វិវាទវិនិយោគរវាងភាគីមួយ និងអ្នកវិនិយោគម្នាក់) តែនៅពេលដែលវិវាទនោះកើតឡើងពីមាត្រា ៨ (ការដកហូត) និង

(iv) នៅក្រោមអនុសញ្ញាស្តីពីពន្ធដារ ដែលទាក់ទងទៅនឹងការគេចពីការបង់ពន្ធត្រួតគ្នា

(ខ) ច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ ឬនីតិវិធីនៃការអនុវត្តទូទៅ ដែលគ្រប់គ្រងលទ្ធកម្ម ដោយទីភ្នាក់ងាររដ្ឋាភិបាលលើទំនិញ និងសេវាកម្ម ដែលត្រូវបានទិញសម្រាប់គោលបំណង រដ្ឋាភិបាល (លទ្ធកម្មរដ្ឋាភិបាល) និងពុំមានគោលបំណងលក់ឡើងវិញដើម្បីពាណិជ្ជកម្ម ឬ គោលបំណងប្រើប្រាស់ក្នុងការផលិតទំនិញ ឬការផ្គត់ផ្គង់សេវាកម្មសម្រាប់ការលក់ដើម្បីពាណិជ្ជកម្ម

(គ) ឧបត្ថម្ភកធន ឬជំនួយដែលផ្តល់អោយដោយភាគីមួយ ឬតាមលក្ខខណ្ឌណាមួយ ដែលភ្ជាប់ទៅនឹងការទទួលបាន ឬការបន្តទទួលបាននូវឧបត្ថម្ភកធន ឬជំនួយទាំងនេះ ទោះបីជាការឧបត្ថម្ភកធន ឬជំនួយទាំងនេះត្រូវបាន ឬមិនត្រូវបានផ្តល់អោយផ្តាច់មុខដល់អ្នកវិនិយោគ និងការវិនិយោគក្នុងស្រុកក៏ដោយ

(ឃ) សេវាកម្ម ដែលផ្គត់ផ្គង់ក្នុងប្រតិបត្តិការរបស់អាជ្ញាធរនៃរដ្ឋាភិបាល ដោយស្ថាប័ន ឬអាជ្ញាធរដែលពាក់ព័ន្ធរបស់ភាគីមួយ ។ សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ សេវាកម្មដែលផ្គត់ផ្គង់ក្នុងប្រតិបត្តិការរបស់អាជ្ញាធរនៃរដ្ឋាភិបាល មានន័យថា សេវាកម្មណាក៏ដោយដែលត្រូវបានផ្គត់ផ្គង់ មិនមែនជាលក្ខណៈពាណិជ្ជកម្ម ឬក្នុងន័យប្រកួតប្រជែងជាមួយអ្នកផ្គត់ផ្គង់សេវាកម្មមួយ ឬច្រើនឡើយ និង

(ង) វិធានការនានាដែលបានប្រកាន់យក ឬរក្សាទុកដោយភាគីមួយ ដែលប៉ះពាល់ដល់ពាណិជ្ជកម្មក្នុងសេវាកម្ម ។

៥. ថ្វីបើមានចែងក្នុងអនុកថាខណ្ឌ ៤(ង) ក៏ដោយ មាត្រា ៧ (ប្រព្រឹត្តកម្មនៃការវិនិយោគ) មាត្រា ៨ (ការដកហូត) មាត្រា ៩ (សំណងសម្រាប់ការខាតបង់) មាត្រា ១០ (ការផ្ទេរ និងការបង្វិលប្រាក់ចំណេញ) មាត្រា ១២ (ឧបាទ្ទេសកម្ម) និងមាត្រា ១៤ (វិវាទវិនិយោគរវាងភាគីមួយ និងអ្នកវិនិយោគម្នាក់) ត្រូវអនុវត្ត *mutatis mutandis* ចំពោះវិធានការណាមួយដែលប៉ះពាល់ដល់ ការផ្គត់ផ្គង់សេវាកម្ម ដោយអ្នកផ្តល់សេវាកម្មរបស់ភាគីមួយ តាមរយៈវត្តមានផ្នែកពាណិជ្ជកម្ម នៅក្នុងដែនដីរបស់ភាគីមួយផ្សេងទៀត ប៉ុន្តែត្រឹមកម្រិតដែលវិវាទទាំងនេះ ទាក់ទងទៅនឹងការវិនិយោគ និងកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះប៉ុណ្ណោះ ដោយមិនគិតថាវិស័យសេវាកម្មមួយ ត្រូវបាន ឬមិនត្រូវបានគ្រោងធ្វើឡើងនៅក្នុងតារាងនៃការប្តេជ្ញាចិត្តជាក់លាក់របស់ភាគីនោះ ក្រោមកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មផ្នែកសេវាកម្មនៃកិច្ចព្រមព្រៀង ក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ដែលបានចុះហត្ថលេខានៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៧ នោះឡើយ ។

## មាត្រា ៤

## ប្រព្រឹត្តិកម្មជាតិ

ភាគីនីមួយៗ នៅក្នុងដែនដីរបស់ខ្លួន ត្រូវផ្តល់អោយអ្នកវិនិយោគនៃភាគីមួយផ្សេងទៀត និងការវិនិយោគរបស់គេនូវប្រព្រឹត្តិកម្ម មិនតិចជាងអ្វីដែលខ្លួនបានផ្តល់សំរាប់អ្នកវិនិយោគរបស់ខ្លួន ក្នុងកាលៈទេសៈដូចគ្នា ទាក់ទងនឹងការគ្រប់គ្រង ការដឹកនាំ ប្រតិបត្តិការ ការថែទាំ ការប្រើប្រាស់ ការលក់ ការជំរះបញ្ជី ឬទម្រង់ផ្សេងៗទៀត នៃការចាត់ចែងការវិនិយោគទាំងនេះ ។

## មាត្រា ៥

## ប្រព្រឹត្តិកម្មជាតិដែលមានភាពអនុគ្រោះបំផុត

១. ភាគីនីមួយៗ ត្រូវផ្តល់អោយចំពោះអ្នកវិនិយោគនៃភាគីមួយផ្សេងទៀត និងការវិនិយោគរបស់គេនូវប្រព្រឹត្តិកម្មមិនតិចជាងអ្វីដែលខ្លួនបានផ្តល់សំរាប់អ្នកវិនិយោគរបស់ភាគីណាមួយផ្សេងទៀត ឬប្រទេសទីបី និង/ឬការវិនិយោគរៀងៗខ្លួន របស់ពួកគេ ក្នុងកាលៈទេសៈដូចគ្នា ទាក់ទងនឹងការអនុញ្ញាត ការបង្កើត

ការទិញយក ការពង្រីក ការគ្រប់គ្រង ការដឹកនាំ កិច្ចដំណើរការ ការថែទាំ ការប្រើប្រាស់ ការជម្រះបញ្ជី ការលក់ ឬទម្រង់ផ្សេងទៀតនៃការចាត់ចែងការ វិនិយោគ ។

២. ទោះបីជាមានចែងក្នុងកថាខ័ណ្ឌទី១នេះក៏ដោយ ប្រសិនបើភាគីមួយផ្តល់អោយអ្នកវិនិយោគនៃភាគីមួយផ្សេងទៀត ឬប្រទេសទីបី និងការវិនិយោគរបស់ពួកគេ ដោយសារកិច្ចព្រមព្រៀង ឬការរៀបចំនាពេលអនាគត ដែលភាគីនោះគឺជាភាគីមួយមាននូវប្រព្រឹត្តិកម្មដែលមានលក្ខណៈអនុគ្រោះជាង ខ្លួននឹងពុំមានកាតព្វកិច្ចផ្តល់ប្រព្រឹត្តិកម្មបែបនេះចំពោះអ្នកវិនិយោគនៃភាគីមួយផ្សេងទៀត និងការវិនិយោគរបស់ពួកគេឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលត្រូវបានស្នើសុំពីភាគីមួយផ្សេងទៀត ខ្លួនត្រូវផ្តល់ឱកាសគ្រប់គ្រាន់ ដើម្បីចរចាអំពីអត្ថប្រយោជន៍ដែលបានផ្តល់អោយនៅក្នុងកិច្ចព្រមព្រៀងនេះ ។

៣. ប្រព្រឹត្តិកម្មដែលមានចែងនៅក្នុងកថាខ័ណ្ឌទី១ និងកថាខ័ណ្ឌទី២ មិនត្រូវរាប់បញ្ចូល :

(ក) ប្រព្រឹត្តិកម្មអនុគ្រោះណាមួយដែលផ្តល់អោយអ្នកវិនិយោគ និងការវិនិយោគរបស់ពួកគេនៅក្រោមកិច្ចព្រមព្រៀងទ្វេភាគីថ្នាក់តំបន់ ឬអន្តរជាតិដែលមានស្រាប់ ឬទម្រង់ណាមួយនៃកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច ឬថ្នាក់តំបន់ជាមួយប្រទេសដែលមិនមែនជាភាគី និង

(ខ) ប្រព្រឹត្តិកម្មអនុគ្រោះដែលមានស្រាប់ ឬនាពេលអនាគត ដែលផ្តល់អោយអ្នកវិនិយោគ និងការ វិនិយោគរបស់ពួកគេនៅក្នុងកិច្ចព្រមព្រៀង ឬការរៀបចំណាមួយរវាង ឬក្នុងចំណោម រដ្ឋសមាជិកអាស៊ាន ឬរវាងភាគីណាមួយ និងដែនដីគយដាច់ដោយឡែករបស់ខ្លួន ។

៤. ដើម្បីភាពជាក់លាក់ជាងនេះ កាតព្វកិច្ចនៅក្នុងមាត្រានេះ ពុំមានលក្ខខណ្ឌតម្រូវអោយភាគីណាមួយពង្រីកទៅដល់អ្នកវិនិយោគនៃភាគីមួយផ្សេងទៀត នូវនីតិវិធីដោះស្រាយវិវាទផ្សេងពីដំណើរការដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះឡើយ ។

## មាត្រា ៦

## វិធានការគ្មានអនុលោមភាព

១. មាត្រា ៤ (ប្រព្រឹត្តិកម្មជាតិ) និងមាត្រា ៥ (ប្រព្រឹត្តិកម្មជាតិដែលមានភាពអនុគ្រោះបំផុត) មិនត្រូវអនុវត្តចំពោះ :

(ក) វិធានការគ្មានអនុលោមភាពដែលមានស្រាប់ ឬថ្មី ដែលត្រូវបានរក្សាទុក ឬប្រកាន់យកនៅក្នុងដែនដីរបស់ខ្លួនឡើយ ។

(ខ) ការបន្ត ឬការធ្វើវិសោធនកម្មនូវវិធានការគ្មានអនុលោមភាព ដែលមានយោងនៅក្នុងអនុកថាខ័ណ្ឌ (ក) ។

២. ភាគីទាំងអស់ត្រូវខិតខំប្រឹងប្រែង ដើម្បីលុបចោលជាបណ្ដើរៗនូវរាល់វិធានការគ្មានអនុលោមភាព ។

៣. ភាគីទាំងអស់ត្រូវធ្វើការពិភាក្សាគ្នា យោងតាមមាត្រា ២៤ (កែប្រែ) ដើម្បីបន្តគោលដៅនៅក្នុងមាត្រា ២(ក) និងមាត្រា ២(ង) ។ ភាគីទាំងអស់ត្រូវខិតខំប្រឹងប្រែង ដើម្បីសម្រេចបាននូវគោលដៅ ដែលត្រូវបានគ្រប់គ្រងដោយស្ថាប័ននៅក្រោមមាត្រា ២២ (កិច្ចព្រមព្រៀងស្ថាប័ន) ។

## មាត្រា ៧

## ប្រព្រឹត្តិកម្មនៃការវិនិយោគ

១. ភាគីនីមួយៗត្រូវផ្ដល់ដល់ការវិនិយោគរបស់អ្នកវិនិយោគនៃភាគីមួយផ្សេងទៀតនូវប្រព្រឹត្តិកម្មប្រកបដោយយុត្តិធម៌ និងសមធម៌ ព្រមទាំងការការពារ និងសន្តិសុខពេញលេញ ។

២. ដើម្បីភាពជាក់លាក់ជាងនេះ :

(ក) ប្រព្រឹត្តិកម្មប្រកបដោយយុត្តិធម៌ និងសមធម៌ សំដៅដល់កាតព្វកិច្ចរបស់ភាគីនីមួយៗក្នុងការមិនបដិសេធយុត្តិធម៌នៅក្នុងបណ្ដឹងផ្លូវច្បាប់ ឬបណ្ដឹងរដ្ឋបាល និង

(ខ) ការការពារ និងសន្តិសុខពេញលេញ តម្រូវអោយភាគីនីមួយៗអនុវត្តវិធានការនានា តាមការចាំបាច់ដោយសមហេតុផលក្នុងការធានាអោយមានការការពារ និងសន្តិសុខនៃការវិនិយោគរបស់អ្នកវិនិយោគនៃភាគីមួយផ្សេងទៀត ។

៣. ការកំណត់ថា មានការប្រព្រឹត្តល្មើសបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ ឬនៃកិច្ចព្រមព្រៀងអន្តរជាតិ ដាច់ដោយឡែក ពុំមានន័យថា មានការប្រព្រឹត្តល្មើសលើមាត្រានេះឡើយ

## មាត្រា ៨

## ការដកហូត

១.　ភាគីមួយមិនត្រូវធ្វើការដកហូត ធ្វើជាតូបនីយកម្ម ឬចាត់វិធានការស្រដៀងគ្នាផ្សេងទៀត ("ការដកហូត") ប្រឆាំងនឹងការវិនិយោគរបស់អ្នកវិនិយោគនៃភាគីមួយ ផ្សេងទៀត លើកលែងតែលក្ខខណ្ឌដូចខាងក្រោមត្រូវបានបំពេញ :

(ក)　សម្រាប់គោលបំណងសាធារណៈ

(ខ)　យោងតាមច្បាប់ក្នុងស្រុកជាធរមាន រួមទាំងនីតិវិធីច្បាប់

(គ)　ត្រូវបានអនុវត្តតាមវិធីដែលគ្មានការរើសអើង និង

(ឃ)　ដោយចេញសំណងស្របតាមកថាខ័ណ្ឌទី២ ។

២.　សំណងបែបនេះត្រូវស្របទៅតាមតម្លៃទីផ្សារត្រឹមត្រូវនៃការវិនិយោគ ដែលត្រូវបានធ្វើការដកហូតនៅពេលដែលការដកហូតត្រូវបានប្រកាសជាសាធារណៈ ឬនៅពេលដែលការដកហូតកើតឡើង ពោលគឺមួយណាដែលកើតមុនគេ ហើយសំណងនេះត្រូវបានផ្ទេរ ដោយសេរីជារូបិយប័ណ្ណដែលអាចប្រើប្រាស់ បានដោយសេរីពីប្រទេសម្ចាស់ផ្ទះ ។ តម្លៃទីផ្សារត្រឹមត្រូវមិនត្រូវឆ្លុះបញ្ចាំងអំពីការប្រែប្រួលណាមួយនៃតម្លៃទីផ្សារ ដែលកើតមានឡើងនោះឡើយ ព្រោះថា ការដកហូតត្រូវបានគេដឹងជាសាធារណៈមុននេះ ។

៣.　សំណងនឹងត្រូវទូទាត់សងដោយពុំមានការពន្យារពេលមិនសមហេតុផលឡើយ ។ ក្នុងករណីដែលមានការពន្យារពេល សំណងត្រូវរាប់បញ្ចូលទាំងការប្រាក់ក្នុងអត្រាការប្រាក់ពាណិជ្ជកម្ម តាមទីផ្សារ គិតចាប់ពីកាលបរិច្ឆេទនៃការដកហូតរហូតដល់កាលបរិច្ឆេទទូទាត់[៦] ។ សំណង រួមទាំងការប្រាក់ដែលកើនឡើង ត្រូវទូទាត់ជារូបិយប័ណ្ណដែលការវិនិយោគត្រូវបានធ្វើឡើងពីដំបូងទី ឬ ប្រសិនបើមានសំនើពីអ្នកវិនិយោគ ជារូបិយប័ណ្ណដែលប្រើប្រាស់ដោយសេរី ។

---

[៦] សម្រាប់ប្រទេសម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន ថៃ និងវៀតណាម ក្នុងករណីដែលមានការពន្យារពេល អត្រា និងការបង់ការប្រាក់នៃសំណងចំពោះការដកហូតនៃការវិនិយោគរបស់វិនិយោគិននៃភាគីមួយផ្សេងទៀត នឹងត្រូវកំណត់យោង តាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយនៃប្រទេសទាំងនេះ ក្នុងលក្ខខណ្ឌថា ច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយ ទាំងនេះត្រូវបានអនុវត្តផ្អែកលើមូលដ្ឋានមិនរើសអើងចំពោះការវិនិយោគរបស់វិនិយោគិននៃភាគីមួយផ្សេងទៀត ឬមិនមែនភាគី ។

៤. ទោះបីជាមានចែងក្នុងកថាខ័ណ្ឌទី១ កថាខ័ណ្ឌទី២ និងកថាខ័ណ្ឌទី៣ នេះក៏ដោយ វិធានការណាមួយស្តីពីការដកហូត ដែលទាក់ទងទៅនឹងជីវិ នឹងត្រូវបានកំណត់នៅក្នុងច្បាប់ និងបទប្បញ្ញត្តិ និងវិសោធនកម្មពាក់ព័ន្ធក្នុងស្រុកដែលមានស្រាប់របស់ភាគីដែលធ្វើការដកហូត ហើយត្រូវឆ្លើយតបតាមគោលបំណង និងពេលវេលាទូទាត់សំណងនៃការដកហូត ស្របតាមច្បាប់ និងបទប្បញ្ញត្តិដែលបានរៀបរាប់នេះ ។

៥. នៅពេលដែលភាគីមួយធ្វើការដកហូតទ្រព្យសម្បត្តិរបស់និតិបុគ្គលមួយ ដែលត្រូវបានបង្កើតឡើងក្រោមច្បាប់ និងបទប្បញ្ញត្តិរបស់ភាគីនោះ ហើយដែលអ្នកវិនិយោគនៃភាគីមួយផ្សេងទៀតកាន់កាប់ភាគ ហ៊ុន ភាគីនោះត្រូវអនុវត្តប្បញ្ញត្តិនៃកថាខ័ណ្ឌមុន១ ដើម្បីធានាថា សំណងត្រូវបានទូទាត់ដល់អ្នកវិនិយោគទាំងនោះ តាមទំហំផលប្រយោជន៍របស់ពួកគេ ចំពោះទ្រព្យសម្បត្តិដែលត្រូវបានដកហូត ។

៦. មាត្រានេះមិនអនុវត្តចំពោះការចេញអាជ្ញាប័ណ្ណដោយបង្ខំ ដែលត្រូវបានផ្តល់ដល់កម្មសិទ្ធិបញ្ញាស្របតាមកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពទាក់ទងនឹងពាណិជ្ជកម្មនៃកម្មសិទ្ធិបញ្ញានៅក្នុងឧបសម្ព័ន្ធ១គ នៃកិច្ចព្រមព្រៀងរបស់ WTO ។

## មាត្រា ៩

## សំណងចំពោះការខាតបង់

អ្នកវិនិយោគនៃភាគីមួយដែលការវិនិយោគរបស់ខ្លួននៅក្នុងដែនដីនៃភាគីមួយ ផ្សេងទៀត ទទួលរងនូវការខាតបង់ ដោយសារសង្គ្រាម ឬជម្លោះប្រដាប់អាវុធផ្សេងទៀត បដិវត្តន៍ ស្ថានភាព អាសន្ន ការបះបោរ ការបះបោរ ឬកុប្បកម្មនៅក្នុងដែនដីនៃភាគីផ្សេងនោះ នឹងត្រូវទទួលបាននូវប្រព្រឹត្តិកម្ម របស់ភាគីផ្សេងនោះទាក់ទងនឹងការ ស្តារឡើងវិញ ការចេញសង សំណង ឬការទូទាត់ផ្សេងទៀត ដែលមាន លក្ខណៈអនុគ្រោះមិនតិចជាងសំណង ដែលភាគីផ្សេងនោះផ្តល់អោយអ្នកវិនិយោគនៃប្រទេសទីបី ឬអ្នកវិនិយោគនៃប្រទេសរបស់ខ្លួនពេលណាមួយណា ដែលមានលក្ខណៈអនុគ្រោះជាង នៅក្នុងកាលៈទេសៈដូចគ្នា ។

## មាត្រា ១០

## ការផ្ទេរ និងការបង្វិលប្រាក់ចំណេញ

១. ទាក់ទងនឹងការវិនិយោគនៅក្នុងដែនដីរបស់ខ្លួននៃអ្នកវិនិយោគរបស់ភាគីផ្សេងទៀត ភាគីនីមួយៗត្រូវអនុញ្ញាតអោយមានការផ្ទេរប្រាក់ទាំងអស់ ជារូបិយប័ណ្ណដែលអាចប្រើប្រាស់ដោយសេរី តាមអត្រាប្តូរប្រាក់លើ

ទីផ្សារ នៅថ្ងៃផ្ទេរ ព្រមទាំងអនុញ្ញាតអោយមានការផ្ទេរប្រាក់ទាំងនេះដោយសេរីនៅក្នុង និងចេញពីដែនដីរបស់ខ្លួន ដោយមិនមានការពន្យារពេល ។ ការផ្ទេរប្រាក់ទាំងនេះរួមមាន :

(ក) មូលធនដើម រួមទាំងមូលធនបន្ថែមណាមួយដែលត្រូវបានប្រើប្រាស់ ដើម្បីរក្សា ឬពង្រីកការវិនិយោគ[៧]

(ខ) ប្រាក់ចំណេញសុទ្ធ ការកើនឡើងនូវមូលធន ភាគលាភ សួយសារ កម្រៃអាជ្ញាប័ណ្ណ ជំនួយបច្ចេកទេស និងថ្លៃបច្ចេកទេស និងគ្រប់គ្រង ការប្រាក់ និងចំណូលចរន្តដទៃទៀត ដែលកើនឡើងពីការវិនិយោគនៃអ្នកវិនិយោគរបស់ភាគីមួយផ្សេងទៀត

(គ) ប្រាក់ចំណូលបានមកពីការលក់សរុប ឬមួយផ្នែក ឬការជម្រះបញ្ជីនៃការវិនិយោគ ដែលធ្វើឡើងដោយអ្នកវិនិយោគនៃភាគីដទៃទៀតណាមួយ

(ឃ) មូលនិធិក្នុងការទូទាត់ប្រាក់ខ្ចី ឬកម្ចីដែលផ្តល់អោយដោយអ្នកវិនិយោគរបស់ភាគីមួយដល់អ្នកវិនិយោគនៃភាគីផ្សេងទៀត ដែលភាគីទាំងអស់ទទួលស្គាល់ថា ជាការវិនិយោគ

(ង) ចំណូលសុទ្ធ និសំណងដទៃទៀតរបស់រូបវន្តបុគ្គលនៃភាគីមួយផ្សេងទៀត ដែលត្រូវបានជួល និងអនុញ្ញាតអោយធ្វើការទាក់ទងទៅនឹងការវិនិយោគនៅក្នុងដែនដីរបស់ខ្លួន

(ច) ការទូទាត់ដែលធ្វើឡើងក្រោមកិច្ចសន្យា ដោយអ្នកវិនិយោគរបស់ភាគីមួយផ្សេងទៀត ឬការវិនិយោគរបស់ពួកគេ រួមទាំងការទូទាត់ដែលធ្វើឡើង យោងតាម ប្រតិបត្តិការកម្ចី និង

(ឆ) ការទូទាត់ដែលធ្វើឡើងយោងតាមមាត្រា ៨ (ការដកហូត) និងមាត្រា ៩ (សំណងសម្រាប់ការខាតបង់) ។

២. ភាគីនីមួយៗយល់ព្រមសំរាប់ការផ្ទេរ ដូចមានយោងនៅក្នុងកថាខ័ណ្ឌទី១ នូវប្រព្រឹត្តិកម្មដែលមានលក្ខណៈអនុគ្រោះដូចដែលបានយល់ព្រមសំរាប់ការផ្ទេរ ដែលកើតចេញពីការវិនិយោគរបស់អ្នកវិនិយោគនៃភាគីមួយផ្សេងទៀត ឬប្រទេសទីបី នៅក្នុងកាលៈទេសៈដូចគ្នា ។

---

[៧] ភាគីទាំងអស់យល់ថា ការយោងទៅលើ "មូលធនដើមបូកមូលធនបន្ថែម ត្រូវបានប្រើប្រាស់ដើម្បីរក្សា ឬពង្រីកការវិនិយោគ" អនុវត្តតែក្រោយពេលការបញ្ចប់សព្វគ្រប់នៃនីតិវិធីដែលបានអនុម័តសម្រាប់ការវិនិយោគចូលក្នុងប្រទេសប៉ុណ្ណោះ ។

៣. ទោះជាមានចែងក្នុងកថាខ័ណ្ឌទី១ និងកថាខ័ណ្ឌទី២ ក៏ដោយ ភាគីមួយអាចទប់ស្កាត់ ឬពន្យារពេលការផ្ទេរតាមរយៈការអនុវត្តច្បាប់ និងបទបញ្ញត្តិរបស់ខ្លួនប្រកបដោយសមធម៌ មិនរើសអើង និងសុចរិត ទាក់ទងនឹង :

(ក) ការក្ស័យធន ការបាត់បង់សមត្ថភាព ឬលទ្ធភាពក្នុងការទូទាត់ ឬការការពារសិទ្ធិរបស់ម្ចាស់បំណុល

(ខ) ការមិនបំពេញតាមលក្ខខណ្ឌផ្ទេររបស់ភាគីម្ចាស់ផ្ទះ ទាក់ទងនឹងពាណិជ្ជកម្ម ឬការជួញដូរមូលប័ត្រ លក្ខខណ្ឌនាពេលអនាគត ជម្រើស ឬឧបករណ៍និស្សន្ទ

(គ) ការមិនបំពេញតាមកាតព្វកិច្ចពន្ធដារ

(ឃ) បទល្មើសព្រហ្មទណ្ឌ និងការប្រមូលផលចំណេញពីឧក្រិដ្ឋកម្ម

(ង) សន្តិសុខសង្គម ការចូលនិវត្តន៍សាធារណៈ ឬគំរោងការសន្សំចាំបាច់

(ច) ការគោរពតាមសាលក្រមនៅក្នុងដំណើរការតាមផ្លូវតុលាការ ឬរដ្ឋបាល

(ឆ) ប្រាក់ចំណេញបានពីការកាត់បន្ថយចំណាយរបស់បុគ្គលិកទាក់ទងនឹងសំណងពលកម្ម ដែលទាក់ទងនឹងគម្រោងវិនិយោគបរទេស ដែលត្រូវបានបិទទ្វារ ក្នុងចំណោមប្រការផ្សេងទៀត និង

(ជ) ការរៀបចំរបាយការណ៍ ឬរក្សាកំណត់ត្រានៃការផ្ទេរ នៅពេលចាំបាច់ ដើម្បីជួយដល់ការអនុវត្តច្បាប់ ឬអាជ្ញាធរនិយ័តកម្មហិរញ្ញវត្ថុ ។

៤. សម្រាប់ភាពជាក់លាក់ជាងនេះ ការផ្ទេរទាំងឡាយដែលមានយោងនៅក្នុងកថាខ័ណ្ឌមុនៗ ត្រូវអនុវត្តតាមបែបបទពាក់ព័ន្ធ ដែលចែងដោយច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុករបស់ភាគីម្ចាស់ផ្ទះ ទាក់ទងនឹងការគ្រប់គ្រងរដ្ឋបាលប្តូរប្រាក់ ដរាបណាច្បាប់ និងបទប្បញ្ញត្តិទាំងនេះមិនត្រូវបានប្រើប្រាស់ជាមធ្យោបាយក្នុងការគេចវេសពីកាតព្វកិច្ចរបស់ភាគីមួយនៅក្រោមកិច្ចព្រមព្រៀងនេះ ។

៥. ពុំមានអ្វីមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាំងអស់ ដែលជាសមាជិករបស់មូលនិធិរូបិយវត្ថុអន្តរជាតិនៅក្រោមមាត្រាទាំងឡាយនៃកិច្ចព្រមព្រៀងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិឡើយ រួមទាំងការប្រើប្រាស់វិធានការប្តូរប្រាក់ ដែលសមស្របទៅតាមមាត្រានៃកិច្ច

ព្រមព្រៀងរបស់ មូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងលក្ខខណ្ឌថា ភាគីមួយមិនត្រូវដាក់ការកំហិតទៅលើប្រតិបត្តិការមូលធនណាមួយ ដោយមិនសមស្របតាមការប្តេជ្ញាចិត្តជាក់លាក់របស់ខ្លួន នៅក្រោមកិច្ចព្រមព្រៀងនេះ ទាក់ទងនឹងប្រតិបត្តិការបែបនេះ លើកលែងតែ :

(ក) ក្រោមមាត្រា ១១ (វិធានការ ដើម្បីការពារសមតុល្យនៃការទូទាត់) ឬ

(ខ) តាមសំណើរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ឬ

(គ) នៅក្នុងករណីលើកលែង នៅពេលដែលចលនានៃមូលធនបណ្តាល ឬគំរាមកំហែងបណ្តាលអោយមានការវិនាសផ្នែកសេដ្ឋកិច្ច ឬហិរញ្ញវត្ថុចំពោះភាគីពាក់ព័ន្ធ ក្នុងលក្ខខណ្ឌថា ការកំហិតបែបនេះមិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាំងអស់ដែលជាសមាជិករបស់ WTO នៅក្រោមកថាខ័ណ្ឌទី១ នៃមាត្រាទី ១១ នៃ GATS ហើយវិធានការនានាត្រូវបានប្រកាន់យក ស្របតាមកថាខ័ណ្ឌទី២ នៃមាត្រា ១១ នៃកិច្ចព្រមព្រៀងនេះ រួមទាំងការកែប្រែនានាដែលចាំបាច់ "*mutatis mutandis*" ។

## មាត្រា ១១

## វិធានការនានាដើម្បីការពារជញ្ជីងទូទាត់

១. ក្នុងករណីដែលជញ្ជីងទូទាត់មានសភាពធ្ងន់ធ្ងរ និងមានការលំបាកផ្នែកហិរញ្ញវត្ថុខាងក្រៅ ឬការគំរាមកំហែងអំពីការលំបាកទាំងនេះ ភាគីមួយអាចប្រកាន់យក ឬរក្សាការកំហិត ទៅលើការវិនិយោគ រួមទាំងការទូទាត់ ឬការផ្ទេរដែលទាក់ទងនឹងការវិនិយោគ ។ គេទទួលស្គាល់ថា សម្ពាធដាក់លាក់ទៅលើជញ្ជីងនៃការទូទាត់របស់ភាគីមួយនៅក្នុង ដំណើរនៃការអភិវឌ្ឍសេដ្ឋកិច្ច អាចតម្រូវអោយមានការប្រើប្រាស់នូវ ការកំហិតដើម្បីធានា ក្នុងចំណោមវិធានការផ្សេងទៀត នូវការថែរក្សាកម្រិតនៃប្រាក់បំរុងផ្នែកហិរញ្ញវត្ថុគ្រប់ គ្រាន់សម្រាប់ការអនុវត្តកម្មវិធីនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួន ។

២. ការកំហិតដែលយោងដល់ក្នុងកថាខ័ណ្ឌទី១ ត្រូវ :

(ក) មានភាពស្របគ្នាទៅនឹងមាត្រានានានៃកិច្ចព្រមព្រៀងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ

(ខ) មិនរើសអើងក្នុងចំណោមភាគីទាំងអស់

(គ) ចៀសវាងការខូចខាតដែលមិនចាំបាច់ចំពោះផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ភាគីដទៃទៀត

(ឃ) មិនលើសពីអ្វីដែលចាំបាច់ ដើម្បីដោះស្រាយស្ថានភាពដែលមានពណ៌នានៅក្នុងកថា ខ័ណ្ឌទី១

(ង) មានលក្ខណៈបណ្តោះអាសន្ន និងបញ្ឈប់សកម្មភាពបន្តិចម្តងៗនៅពេលដែលស្ថានភាពដូចមានបង្ហាញនៅក្នុងកថាខ័ណ្ឌទី១ ត្រូវបានកែលម្អ និង

(ច) ត្រូវបានអនុវត្តដើម្បីអោយភាគីមួយផ្សេងទៀត ទទួលបាននូវប្រព្រឹត្តកម្មមានភាពអនុគ្រោះមិនតិចជាងប្រទេសទីបីណាមួយ ។

៣. ការដាក់កំហិតណាមួយដែលត្រូវបានប្រកាន់យក ឬរក្សាទុកដោយភាគីមួយក្រោមកថាខ័ណ្ឌទី១ ឬការផ្លាស់ប្តូរណាមួយដែលមាននៅក្នុងកថាខ័ណ្ឌនោះ នឹងត្រូវបានជូនដំណឹងភ្លាមៗទៅគ្រប់ភាគីផ្សេងទៀត ។

## មាត្រា ១២

## ឧបាទ្ទេសកម្ម

១. ក្នុងករណីដែលភាគីណាមួយ ឬទីភ្នាក់ងារណាមួយ ស្ថាប័ន អង្គភាពច្បាប់ ឬសាជីវកម្មដែលត្រូវបានតែងតាំង ដោយភាគី ឬទីភ្នាក់ងារនោះ ដោយសារលទ្ធផលនៃសំណងដែលខ្លួនបានផ្តល់ទាក់ទងនឹងការវិនិយោគ ឬផ្នែកណាមួយនៃការវិនិយោគ ធ្វើការទូទាត់អោយអ្នកវិនិយោគរបស់ខ្លួនទាក់ទិនទៅនឹងការទាមទារណា មួយរបស់ពួកគេនៅក្រោមកិច្ចព្រមព្រៀងនេះ ភាគីដទៃទៀតទាំងអស់ដែលពាក់ព័ន្ធត្រូវទទួលស្គាល់ថា ភាគី ឬទីភ្នាក់ងារ ស្ថាប័ន អង្គភាពច្បាប់ ឬសាជីវកម្មដែលតែងតាំងដោយភាគី ឬទីភ្នាក់ងារនោះ មានសិទ្ធិតាមរយៈឧបាទ្ទេសកម្ម ក្នុងការអនុវត្តសិទ្ធិ និងធ្វើការទាមទារពីអ្នកវិនិយោគរបស់ខ្លួន ។ សិទ្ធិនៃឧបាទ្ទេសកម្ម ឬការទាមទារ មិនត្រូវមានវិសាលភាពធំជាងសិទ្ធិ ឬការទាមទារដើមរបស់អ្នកវិនិយោគដែលបានពោលនេះឡើយ ។

២. នៅពេលដែលភាគី ឬទីភ្នាក់ងារណាមួយ ស្ថាប័ន អង្គភាពច្បាប់ ឬសាជីវកម្ម ដែលខ្លួនបានតែងតាំង បានធ្វើការទូទាត់ទៅអោយអ្នកវិនិយោគរបស់ភាគីនោះ ហើយបានកាន់កាប់សិទ្ធិ និងការទាមទាររបស់អ្នកវិនិយោគ អ្នកវិនិយោគនោះមិនត្រូវប្រើប្រាស់សិទ្ធិ និងការទាមទារទាំងនោះប្រឆាំងនឹងភាគីដទៃទៀតឡើយ លើកលែងតែ ត្រូវបានអនុញ្ញាតអោយបំពេញការងារជំនួសអោយភាគី ឬទីភ្នាក់ងារនោះ ស្ថាប័ន អង្គភាពច្បាប់ ឬសាជីវកម្ម ដែលខ្លួនបានតែងតាំងអោយធ្វើការបង់ប្រាក់ ។

## មាត្រា ១៣

## វិវាទរវាងភាគីទាំងអស់

បញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ដែលចុះហត្ថលេខានៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ នឹងអនុវត្តចំពោះការដោះស្រាយវិវាទរវាង ឬក្នុងចំណោមភាគីទាំងអស់នៅក្រោមកិច្ចព្រមព្រៀងនេះ ។

## មាត្រា ១៤

## វិវាទវិនិយោគរវាងភាគីមួយ និងអ្នកវិនិយោគម្នាក់

១. មាត្រានេះនឹងត្រូវអនុវត្តចំពោះវិវាទវិនិយោគរវាងភាគីមួយ និងអ្នកវិនិយោគម្នាក់របស់ភាគីមួយផ្សេងទៀត ដែលទាក់ទងនឹងការចោទប្រកាន់អំពីការប្រព្រឹត្តល្មើសកាតព្វកិច្ចរបស់ភាគីនៅក្រោមមាត្រា ៤ (ប្រព្រឹត្តិកម្មជាតិ) មាត្រា ៥ (ប្រព្រឹត្តិកម្មជាតិដែលមានភាពអនុគ្រោះបំផុត) មាត្រា ៧ (ប្រព្រឹត្តិកម្មវិនិយោគ) មាត្រា ៨ (ការដកហូត) មាត្រា ៩ (សំណងសម្រាប់ការខាតបង់) និងមាត្រា ១០ (ការផ្ទេរ និងបង្វិលប្រាក់ ចំណេញ) ដែលបណ្តាលអោយមានការខាតបង់ ឬខូចខាតដល់អ្នកវិនិយោគនឹងការវិនិយោគរបស់គេ ទាក់ទិនទៅ នឹងការគ្រប់គ្រង ការដឹកនាំ ប្រតិបត្តិការ ឬការលក់ ឬការចាត់ចែងដទៃទៀតនៃការវិនិយោគ ។

២. មាត្រានេះមិនត្រូវអនុវត្ត :

(ក) ចំពោះវិវាទវិនិយោគ កើតចេញក្រៅព្រឹត្តិការណ៍ដែលបានកើតឡើង ឬវិវាទវិនិយោគដែលបានដោះស្រាយរួចហើយ ឬកំពុងស្ថិតក្រោមដំណើរការតុលាការ ឬមជ្ឈត្តវិនិច្ឆ័យ មុនពេលនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ

(ខ) ក្នុងករណីដែលអ្នកវិនិយោគមានវិវាទកាន់សញ្ជាតិ ឬជាសញ្ជាតិនៃភាគីមានវិវាទ ។

៣. ភាគីទាំងអស់នៃវិវាទ ត្រូវដោះស្រាយវិវាទតាមរយៈការពិគ្រោះយោបល់ ប្រសិនបើអាចធ្វើទៅបាន ។

៤. ប្រសិនបើវិវាទមិនអាចដោះស្រាយបានដូចមានចែងនៅក្នុងកថាខ័ណ្ឌទី៣ ក្នុងរយៈពេលប្រាំមួយ (៦) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការស្នើសុំជាលាយលក្ខណ៍អក្សរអោយមានការពិគ្រោះយោបល់ និងការ ចរចា

លើកលែងតែភាគីទាំងអស់នៃវិវាទព្រមព្រៀងផ្សេងពីនេះ វិវាទនោះអាចត្រូវបានដាក់ជូនតាមជម្រើសរបស់អ្នកវិនិយោគ :

(ក) តុលាការ ឬសាលាក្តីរដ្ឋបាលរបស់ភាគីមានវិវាទ ក្នុងលក្ខខណ្ឌថា តុលាការ ឬសាលាក្តីរដ្ឋបាលទាំងនេះមានយុត្តាធិការ ឬ

(ខ) នៅក្រោមអនុសញ្ញាស្តីពី *មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ដោះស្រាយវិវាទវិនិយោគ (ICSID)* និង*វិធាននៃនីតិវិធី ICSID សម្រាប់ដំណើរការមជ្ឈត្តវិនិច្ឆ័យ* ៨[៨] ក្នុងលក្ខខណ្ឌថា ភាគីមានវិវាទ និងភាគីគ្មានវិវាទ គឺជាភាគីនៃអនុសញ្ញាស្តីពី ICSID ឬ

(គ) នៅក្រោម*វិធានគ្រប់គ្រងយន្តការផ្តល់សេវាកម្មបន្ថែម ICSID* ក្នុងលក្ខខណ្ឌថា ភាគីមានវិវាទ ឬភាគីគ្មានវិវាទ គឺជាភាគីនៃ*អនុសញ្ញា ICSID* ឬ

(ឃ) មជ្ឈត្តវិនិច្ឆ័យក្រោមវិធានរបស់គណៈកម្មការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ ឬ

(ង) ប្រសិនបើភាគីមានវិវាទទាំងអស់ព្រមព្រៀងគ្នាថា ត្រូវដាក់ជូនស្ថាប័នមជ្ឈត្តវិនិច្ឆ័យដទៃណាមួយ ឬក្រោមវិធានមជ្ឈត្តវិនិច្ឆ័យដទៃណាមួយ ។

៥. ក្នុងករណីដែលវិវាទត្រូវបានដាក់ជូនតុលាការក្នុងស្រុកដែលមានសមត្ថកិច្ច វិវាទនោះអាចត្រូវបានដាក់ជូនតុលាការដោះស្រាយវិវាទអន្តរជាតិ ក្នុងលក្ខខណ្ឌថា អ្នកវិនិយោគដែលពាក់ព័ន្ធបានដកសំណុំរឿងរបស់ខ្លួនពីតុលាការក្នុងស្រុកមុនពេលសាលក្រមស្ថាពរត្រូវបានធ្វើឡើងចំពោះសំណុំរឿងនោះ ។ សំរាប់ករណីប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និងវៀតណាម នៅពេលដែលអ្នកវិនិយោគបានដាក់វិវាទទៅកាន់តុលាការមានសមត្ថកិច្ចរបស់ខ្លួន ឬសាលាក្តីរដ្ឋបាល ឬនីតិវិធីមជ្ឈត្តវិនិច្ឆ័យណាមួយដែលមានចែងនៅក្នុងអនុកថាខ័ណ្ឌទី៤(ខ) ៤(គ) ៤(ឃ) ឬ ៤(ង) ជម្រើសនៃនីតិវិធី គឺជាជម្រើសស្ថាពរ ។

៦. ការដាក់វិវាទដើម្បីធ្វើការសម្រុះសម្រួល ឬដើម្បីធ្វើមជ្ឈត្តវិនិច្ឆ័យ ក្រោមអនុកថាខ័ណ្ឌទី៤(ខ) ៤(គ) ៤(ឃ) ឬ ៤(ង) ស្របតាមបទប្បញ្ញត្តិនៃមាត្រានេះ ត្រូវមានលក្ខខណ្ឌ បន្ទាប់ពី :

(ក) ការដាក់វិវាទដើម្បីធ្វើការសម្រុះសម្រួល ឬដើម្បីធ្វើមជ្ឈត្តវិនិច្ឆ័យនោះ ត្រូវធ្វើឡើងក្នុងរយៈពេលបី (៣) ឆ្នាំ ដែលក្នុងរយៈពេលនោះ អ្នកវិនិយោគដែលមានវិវាទបានដឹង ឬគប្បីបានដឹង

---

[៨] ក្នុងករណីនៃប្រទេសហ្វីលីពីន ការដាក់ជូនការទាមទារនៅក្រោម *អនុសញ្ញាស្តីពី ICSID* និង*វិធាននៃនីតិវិធីសម្រាប់ដំណើរការមជ្ឈត្តការ* ត្រូវស្ថិតក្រោមកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងភាគីមានវិវាទទាំងអស់ ក្នុងករណីដែលមានវិវាទវិនិយោគកើតឡើង ។

ដោយសមហេតុផលអំពីការប្រព្រឹត្តល្មើសកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ ដែលបណ្តាលអោយមានការខាតបង់ ឬការខូចខាតចំពោះអ្នកវិនិយោគ ឬការវិនិយោគរបស់ខ្លួន និង

(ខ) អ្នកវិនិយោគមានវិវាទបានផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដែលនឹងត្រូវដាក់ជូនយ៉ាងហោចណាស់កៅសិប (៩០) ថ្ងៃ មុនពេលការទាមទារត្រូវបានដាក់ជូនដល់ភាគីមានវិវាទ អំពីបំណងរបស់ខ្លួនក្នុងការដាក់វិវាទដើម្បីធ្វើការសម្រុះសម្រួល ឬដើម្បីធ្វើមជ្ឈត្តវិនិច្ឆ័យ ។ ក្រោយ ពេលទទួលលិខិតជូនដំណឹងនេះ ភាគីមានវិវាទអាចតម្រូវអោយអ្នកវិនិយោគមាន វិវាទត្រួតពិនិត្យនីតិវិធីពិនិត្យមើលឡើងវិញនូវផ្នែករដ្ឋបាលក្នុងស្រុក ដែលគួសបញ្ជាក់ដោយ ច្បាប់ និង បទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន មុនពេលដាក់វិវាទនៅក្រោមអនុកថាខ័ណ្ឌទី៤(ខ) ៤(គ) ៤(ឃ) ឬ ៤(ង) ។ ការជូនដំណឹងត្រូវ :

(i) កំណត់អនុកថាខ័ណ្ឌទី៤(ខ) ៤(គ) ៤(ឃ) ឬ ៤(ង) ជាវេទិកាសម្រាប់ការដោះស្រាយវិវាទ ហើយក្នុងករណីនៃអនុកថាខ័ណ្ឌទី៤(ខ) កំណត់ថាតើត្រូវស្វែងរកការសម្រុះសម្រួល ឬការធ្វើមជ្ឈត្តវិនិច្ឆ័យ

(ii) បោះបង់សិទ្ធិក្នុងការចាប់ផ្តើម ឬបន្តដំណើរការក្តី ដោយមិនរាប់បញ្ចូលដំណើរការក្តីសម្រាប់វិធានការបណ្តោះអាសន្ននៃការការពារដែលមានយោងដល់កថាខ័ណ្ឌទី ៧ មុនពេលវេទិកាដោះស្រាយវិវាទណាមួយក្នុងចំណោមវេទិកាដោះស្រាយវិវាទដទៃទៀត ដោយយោងដល់កថាខ័ណ្ឌទី៤ ទាក់ទងទៅនឹងបញ្ហាដែលមាន វិវាទ និង

(iii) សង្ខេបត្រួសៗអំពីការចោទប្រកាន់ទាក់ទងនឹងការប្រព្រឹត្តល្មើសរបស់ភាគីមានវិវាទនៅក្រោមកិច្ចព្រមព្រៀងនេះ រួមទាំងមាត្រាដែលត្រូវបានចោទប្រកាន់ថាត្រូវបានប្រព្រឹត្តល្មើស ព្រមទាំងការខាតបង់ ឬការខូចខាតចំពោះអ្នកវិនិយោគ ឬការវិនិយោគរបស់គេ ។

៧. គ្មានភាគីណាមួយត្រូវរារាំងអ្នកវិនិយោគមានវិវាទមិនអោយស្វែងរកវិធានការការពារបណ្តោះអាសន្ន ដែលមិនពាក់ព័ន្ធនឹងការបង់សំណងខូចខាត ឬដំណោះស្រាយលើខ្លឹមសារនៃបញ្ហាមានវិវាទនៅចំពោះមុខតុលាការ ឬសាលាក្តីរដ្ឋបាលរបស់ភាគីមានវិវាទឡើយ មុនពេលស្ថាប័នដំណើរការរឿងក្តី នៅចំពោះមុខវេទិកាដោះស្រាយវិវាទណាមួយ ដោយយោងដល់កថាខ័ណ្ឌទី៤ សម្រាប់ការរក្សាសិទ្ធិ និងផលប្រយោជន៍របស់ខ្លួន ។

៨. គ្មានភាគីណាមួយត្រូវផ្តល់ការការពារផ្នែកការទូត ឬដាក់ការទាមទារជាអន្តរជាតិទាក់ទងនឹងវិវាទ ដែលអ្នកវិនិយោគណាម្នាក់ក្នុងចំណោមអ្នកវិនិយោគរបស់ខ្លួន និងភាគីណាមួយក្នុងចំណោមភាគីដទៃទៀតត្រូវ

យល់ព្រមក្នុងការដាក់ជូន ឬបានដាក់ជូន ដើម្បីធ្វើការសម្រុះសម្រួល ឬធ្វើមជ្ឈត្តវិនិច្ឆ័យនៅក្រោមមាត្រានេះឡើយ លើកលែងតែភាគីដទៃទៀតខកខានមិនបានគោរពតាមសេចក្តីសម្រេចដែលបានធ្វើឡើងចំពោះវិវាទនេះ ។ ការការពារផ្នែកការទូតសម្រាប់គោលបំណងនៃកថាខ័ណ្ឌនេះ មិនត្រូវរាប់បញ្ចូលនូវរាល់ទំនាក់ទំនងផ្នែកការទូតក្រៅផ្លូវការ សម្រាប់តែគោលបំណងនៃការសម្របសម្រួលការដោះស្រាយវិវាទនោះឡើយ ។

៩. នៅពេលដែលអ្នកវិនិយោគណាម្នាក់អះអាងថា ភាគីមានវិវាទបានប្រព្រឹត្តល្មើសមាត្រា ៨ (ការដកហូត) តាម រយៈការប្រកាន់យក ឬការអនុវត្តវិធានការពន្ធដារនោះ ភាគីមានវិវាទ និងភាគីគ្មានវិវាទ បន្ទាប់ពីទទួលបាននូវសំណើពីភាគីមានវិវាទ ត្រូវបើកកិច្ចពិភាក្សា ដើម្បីកំណត់ថា តើវិធានការពន្ធដារនេះមានអានុភាពស្មើនឹងការដកហូត ឬការធ្វើជាតូបនីយកម្មដែរឬទេ? ។ សាលាក្តីណាមួយដែលអាចត្រូវបានបង្កើតឡើងក្រោមមាត្រានេះ ត្រូវផ្តល់ការពិចារណាអោយបានហ្មត់ចត់ចំពោះសេចក្តីសម្រេចរបស់ភាគីទាំងពីរនៅក្រោមកថាខ័ណ្ឌនេះ ។

១០. ប្រសិនបើភាគីទាំងពីរខកខានមិនបានផ្តួចផ្តើមការពិគ្រោះយោបល់បែបនេះ ឬខកខានមិនបានកំណត់ថា តើវិធានការពន្ធដារនេះមានអានុភាពស្មើនឹងការដកហូត ឬការធ្វើជាតូបនីយកម្មដែរឬទេនោះ ក្នុងរយៈពេលមួយរយប៉ែតសិប (១៨០) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបាននូវសំណើសម្រាប់ការពិគ្រោះយោបល់យោងតាម កថាខ័ណ្ឌទី៤ អ្នកវិនិយោគមានវិវាទ មិនត្រូវបានរារាំងពីការដាក់ពាក្យទាមទាររបស់ខ្លួន ដើម្បីធ្វើមជ្ឈត្តវិនិច្ឆ័យ ស្របតាមមាត្រានេះឡើយ ។

## មាត្រា ១៥

## ការបដិសេធផលប្រយោជន៍

១. យោងតាមការជូនដំណឹង និងការពិគ្រោះយោបល់ជាមុន ភាគីមួយអាចបដិសេធផលប្រយោជន៍នៃកិច្ចព្រមព្រៀងនេះ ចំពោះ :

(ក) អ្នកវិនិយោគនៃភាគីមួយផ្សេងទៀត ដែលការវិនិយោគកំពុងត្រូវបានធ្វើឡើងដោយនីតិបុគ្គលដែលត្រូវបានកាន់កាប់ ឬគ្រប់គ្រងដោយបុគ្គលនៃប្រទេសមិនមែនភាគី ហើយដែលនីតិបុគ្គលនោះគ្មានប្រតិបត្តិការអាជីវកម្មធំដុំនៅក្នុងដែនដីរបស់ភាគីមួយផ្សេងទៀត ឬ

(ខ) អ្នកវិនិយោគនៃភាគីមួយផ្សេងទៀត ដែលការវិនិយោគកំពុងត្រូវបានធ្វើឡើងដោយនីតិបុគ្គលមួយ ដែលត្រូវបានកាន់កាប់ ឬគ្រប់គ្រងដោយបុគ្គលរបស់ភាគីដែលបដិសេធ ។

២. ថ្វីបើមានក្នុងកថាខ័ណ្ឌទី១ ក៏ដោយ សំរាប់ករណីប្រទេសថៃឡង់ដ៍ ក្រោមច្បាប់ និង/ឬបទប្បញ្ញត្តិជាធរមានរបស់ខ្លួន អាចបដិសេធផលប្រយោជន៍នៃកិច្ចព្រមព្រៀងនេះ ទាក់ទងទៅនឹងការអនុញ្ញាត ការបង្កើត ការទទួលបាន និងការពង្រីកការវិនិយោគចំពោះអ្នកវិនិយោគនៃភាគីដទៃទៀត ដែលជានីតិបុគ្គលរបស់ភាគីនោះ និងចំពោះការវិនិយោគរបស់អ្នកវិនិយោគនោះ ដែលប្រទេសថៃឡង់ដ៍គួសបញ្ជាក់ថា នីតិបុគ្គលនោះ[៩] ត្រូវបានកាន់កាប់ ឬគ្រប់គ្រងដោយរូបវ័ន្តបុគ្គល ឬនីតិបុគ្គលនៃប្រទេសមិនមែនជាភាគី ឬភាគីដែលបដិសេធ ។

៣. ដោយមិនប៉ះពាល់ដល់កថាខ័ណ្ឌទី១ ប្រទេសហ្វីលីពីនអាចបដិសេធផលប្រយោជន៍នៃកិច្ចព្រមព្រៀងនេះចំពោះអ្នកវិនិយោគរបស់ភាគីមួយផ្សេងទៀត និងចំពោះការវិនិយោគរបស់អ្នកវិនិយោគនោះ ដែលខ្លួនគួសបញ្ជាក់ថា អ្នកវិនិយោគនោះបានធ្វើវិនិយោគដោយប្រព្រឹត្តល្មើសទៅនឹងបទប្បញ្ញត្តិនានានៃច្បាប់សហធនលេខ ១០៨ ដែល មានចំណងជើងថា "ច្បាប់ស្តីពីការដាក់ពិន័យចំពោះអំពើគេចវេសពីច្បាប់ ស្តីពីការធ្វើជាតូបនីយកម្មនូវសិទ្ធិ សិទ្ធិលក់ដូរ ឬជួញ ដែលទទួលបានពីម្ចាស់ដើម ឬបុព្វសិទ្ធ" ដូចត្រូវបានធ្វើវិសោធនកម្មដោយក្រឹត្យច្បាប់របស់ប្រធានាធិបតីលេខ ៧០៥ ដែលគេស្គាល់ថាជា "ច្បាប់ប្រឆាំងនឹងភាពល្ងង់" ដូចដែលអាចត្រូវបានធ្វើវិសោធនកម្ម ។

## មាត្រា ១៦

## ការលើកលែងទូទៅ

១. អនុលោមតាមលក្ខខណ្ឌតំរូវដែលថាវិធានការទាំងនោះ មិនត្រូវបានអនុវត្តជាមធ្យោបាយអាជ្ញាកណ្តាល ឬជាមធ្យោបាយរើសអើង គ្មានមូលដ្ឋាន ឬមិនសមហេតុផលរវាងភាគីទាំងអស់ ឬរវាងអ្នកវិនិយោគរបស់ពួកគេ ដែលសំរាប់លក្ខណខណ្ឌដូចគ្នានោះ មានឧត្តមភាព ឬការកំណត់កំហិតមិនច្បាស់លាស់

---

[៩] (ក) សំរាប់ករណីប្រទេសថៃ នីតិបុគ្គលដែលយោងដល់នៅក្នុងមាត្រានេះ គឺ :

(i) "ត្រូវបានកាន់កាប់" ដោយរូបវ័ន្តបុគ្គល ឬនីតិបុគ្គលរបស់ភាគីមួយ ឬប្រទេសមិនមែនជាភាគី ប្រសិនបើជាងហាសិប (៥០) ភាគរយ នៃភាគហ៊ុននៅក្នុងភាគីនោះ ត្រូវបានកាន់កាប់ជាអត្ថប្រយោជន៍ដោយបុគ្គលទាំង នោះ ។

(ii) "ត្រូវបានគ្រប់គ្រង" ដោយរូបវ័ន្តបុគ្គល ឬនីតិបុគ្គលរបស់ភាគីមួយ ឬប្រទេសមិនមែនជាភាគី ប្រសិនបើបុគ្គលទាំងនេះមានសិទ្ធិអំណាចក្នុងការតែងតាំងភាគច្រើននៃអភិបាលក្នុងក្រុមប្រឹក្សាភិបាល ឬបើមិនដូច្នោះទេ អាចណែនាំអំពីវិធានការរបស់ខ្លួន ដោយស្របច្បាប់ ។

(ខ) ក្នុងករណីនៃប្រទេសឥណ្ឌូនេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន និងវៀតណាម កម្មសិទ្ធិ និងការគ្រប់គ្រងនឹងត្រូវបានកំណត់នៅក្នុងច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក ។

ចំពោះអ្នកវិនិយោគ ឬការវិនិយោគរបស់ពួកគេ ដែលធ្វើឡើងដោយអ្នកវិនិយោគរបស់ភាគីមួយផ្សេងទៀត នោះ គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយដើម្បីទប់ស្កាត់ចំពោះការប្រកាន់យក ឬការអនុវត្ត ដោយភាគីណាមួយ នូវវិធានការ :

(ក) ចាំបាច់ ដើម្បីការពារសីលធម៌សាធារណៈ ឬដើម្បីថែរក្សានូវសណ្តាប់ធ្នាប់សាធារណៈ១០[១០]

(ខ) ចាំបាច់ ដើម្បីការពារជីវិត ឬសុខភាពរបស់មនុស្ស សត្វ ឬរុក្ខជាតិ

(គ) ចាំបាច់ ដើម្បីធានាបាននូវការគោរពតាមច្បាប់ ឬបទប្បញ្ញត្តិ ដែលមានសង្គតភាពជាមួយបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ រាប់បញ្ចូលទាំងបញ្ហាពាក់ព័ន្ធដូចខាងក្រោម :

(i) ទប់ស្កាត់ការប្រព្រឹត្តិនូវអំពើឆបោក និងការលួចបន្លំដើម្បីដោះស្រាយផលប៉ះពាល់នៃការមិនអនុវត្តតាមកិច្ចសន្យា

(ii) ការការពារឯកជនភាពនៃបុគ្គល ទាក់ទងនឹងដំណើរការ និងការផ្សព្វផ្សាយទិន្នន័យផ្ទាល់ខ្លួន និងការការពារការសំងាត់នៃប្រវត្តិ និងគណនីរបស់បុគ្គល

(iii) សុវត្ថិភាព

(ឃ) មានគោលបំណងធានានូវការដាក់កំហិតអោយបង់ពន្ធ ឬការប្រមូល ប្រកបដោយសមធម៌ ឬប្រសិទ្ធភាព១១[១១] នូវពន្ធដារផ្ទាល់ ទាក់ទងនឹងការវិនិយោគ ឬអ្នកវិនិយោគរបស់ភាគីណាមួយ

(ង) តំរូវអោយការការពាររតនសម្បត្តិជាតិដែលមានតម្លៃខាងសិល្បៈ តម្លៃខាងប្រវត្តិសាស្ត្រ ឬតម្លៃខាងបុរាណវិទ្យា ឬ

(ច) ទាក់ទងនឹងការអភិរក្សធនធានធម្មជាតិដែលជិតបាត់បង់ ប្រសិនបើវិធានការទាំងនេះត្រូវបានធ្វើឡើងប្រកបដោយប្រសិទ្ធភាពរួមជាមួយនឹងការកំហិតលក្ខខណ្ឌលើផលិតកម្ម ឬការប្រើប្រាស់ក្នុងស្រុក

---

[១០] សំរាប់គោលបំណងនៃអនុកថាខ័ណ្ឌនេះ កំណត់សំគាល់ទី ៥ នៃមាត្រា ១៤ នៃ GATS ត្រូវបានរួមបញ្ចូលទៅក្នុង និងបង្កើតបានជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ រួមបញ្ចូលទាំងការកែប្រែ ។

[១១] សំរាប់គោលបំណងនៃអនុកថាខ័ណ្ឌនេះ កំណត់សំគាល់ទី ៦ នៃមាត្រា ១៤ នៃ GATS ត្រូវបានរួមបញ្ចូលទៅក្នុង និងបង្កើតបានជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ រួមបញ្ចូលទាំងការកែប្រែ ។

២.	ចំពោះវិធានការណាដែលជះឥទ្ធិពលលើការផ្តត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ កថាខ័ណ្ឌទី ២ (បទប្បញ្ញត្តិក្នុងស្រុក) នៃឧបសម្ព័ន្ធស្តីពីសេវាកម្មហិរញ្ញវត្ថុនៃ GATS ដែលត្រូវរួមបញ្ចូលទៅក្នុង និងបង្កើតបានជាផ្នែកមួយទាំងស្រុងនៃកិច្ចព្រមព្រៀងនេះ រួមទាំងការកែប្រែចាំបាច់ដែលបានធ្វើឡើង ។

## មាត្រា ១៧

## ការលើកលែងផ្នែកសន្តិសុខ

គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវបានបកស្រាយ :

(ក)	ដើម្បីតម្រូវអោយភាគីណាមួយផ្តល់ព័ត៌មានណាមួយ ដែលការផ្សព្វផ្សាយព័ត៌មាននោះ ខ្លួនយល់ឃើញថាផ្ទុយទៅនឹងផលប្រយោជន៍ផ្នែកសន្តិសុខរបស់ខ្លួន ឬ

(ខ)	ដើម្បីរារាំងភាគីណាមួយ មិនអោយអនុវត្តសកម្មភាពដែលខ្លួនយល់ឃើញថា ចាំបាច់សំរាប់ការការពារផលប្រយោជន៍ផ្នែកសន្តិសុខរបស់ខ្លួន រាប់បញ្ចូលទាំង ប៉ុន្តែមិនកំហិតចំពោះ :

(i)	សកម្មភាពទាក់ទងនឹងសម្ភារៈដែលអាចផ្ទុះ និងអាចរលាយ ឬសំភារៈ ដែលមានប្រភពចេញពីសំភារៈខាងលើនេះ

(ii)	សកម្មភាពទាក់ទងនឹងចរាចរអាវុធ គ្រាប់រំសេវ និងសញ្ញាវុធសង្គ្រាម នឹងចរាចរសម្ភារៈផ្សេងៗទៀត ដែលមានគោលបំណងផ្គត់ផ្គង់ដោយផ្ទាល់ ឬដោយប្រយោលដល់មូលដ្ឋានទ័ព

(iii)	សកម្មភាព ដែលធ្វើឡើងដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈសំខាន់ៗប្រឆាំងនឹងការប៉ុនប៉ងដោយចេតនា ដើម្បីបំផ្លាញ ឬធ្វើអោយអន់ថយដល់ហេដ្ឋារចនាសម្ព័ន្ធទាំងនោះ

(iv)	សកម្មភាព ដែលធ្វើឡើងក្នុងកាលៈទេសៈសង្គ្រាម ឬភាពអាសន្នផ្សេងទៀតក្នុងទំនាក់ទំនងក្នុងស្រុក ឬអន្តរជាតិ

(គ)	ដើម្បីទប់ស្កាត់ភាគីណាមួយមិនអោយចាត់វិធានការណាមួយ ដោយយោងដល់កាតព្វកិច្ច ដូចមានចែងក្នុងធម្មនុញ្ញសហប្រជាជាតិសំរាប់ការថែរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ ។

## មាត្រា ១៨

## ភាគពួកិច្ចផ្សេងទៀត

១. ប្រសិនបើនីតិកម្មរបស់ភាគីណាមួយ ឬកាតព្វកិច្ចជាអន្តរជាតិ ដែលកើតមានឡើងនៅពេលនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ឬត្រូវបានបង្កើតឡើងនៅពេលបន្ទាប់មកទៀត រវាង ឬក្នុងចំណោមភាគីទាំងអស់ បណ្តាលអោយមានស្ថានភាពមួយដែលផ្តល់លទ្ធភាពដល់ការវិនិយោគដោយអ្នកវិនិយោគរបស់ភាគីមួយផ្សេងទៀតអោយទទួលបានប្រព្រឹត្តិកម្មដែលអនុគ្រោះជាងប្រព្រឹត្តិកម្ម ដែលផ្តល់អោយក្រោមកិច្ចព្រមព្រៀងនេះ ស្ថានភាពនោះនឹងមិនត្រូវបានប៉ះពាល់ដោយកិច្ចព្រមព្រៀងនេះឡើយ ។

២. ភាគីនីមួយៗត្រូវគោរពតាមការប្តេជ្ញាចិត្តដែលខ្លួនបានធ្វើឡើងជាមួយអ្នកវិនិយោគរបស់ភាគីមួយផ្សេងទៀត ទាក់ទងទៅនឹងការវិនិយោគរបស់ពួកគេ ។

## មាត្រា ១៩

## តម្លាភាព

១. ដើម្បីសំរេចបាននូវគោលបំណងនៃកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗ ត្រូវ :

(ក) បង្កើតអោយមានច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ និងគោលការណ៍ណែនាំរដ្ឋបាល ដែលពាក់ព័ន្ធទាំងអស់ ស្តីពីការអនុវត្តទូទៅ ដែលទាក់ទិននឹង ឬប៉ះពាល់ដល់ការវិនិយោគនៅក្នុងដែនដីរបស់ខ្លួន តាមរយៈការបោះពុម្ពផ្សាយ ។

(ខ) ជូនដំណឹងភ្លាមៗ ឬយ៉ាងហោចណាស់ជាប្រចាំឆ្នាំដល់ភាគីដទៃទៀតអំពីការដាក់អោយប្រើប្រាស់នូវច្បាប់ថ្មីណាមួយ ឬការកែប្រែណាមួយទៅលើច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ ឬគោលការណ៍ណែនាំរដ្ឋបាលដែលមានស្រាប់របស់ខ្លួន ដែលប៉ះពាល់ខ្លាំងទៅលើការវិនិយោគនៅក្នុងដែនដីរបស់ខ្លួន ឬការប្តេជ្ញាចិត្តរបស់ខ្លួននៅក្រោមកិច្ចព្រមព្រៀងនេះ ។

(គ) បង្កើត ឬតែងតាំងកន្លែងស៊ើបសួរ ដែលនៅពេលទទួលបានសំណើរបស់រូបវ័ន្តបុគ្គល នីតិបុគ្គល ឬអ្នកណាម្នាក់របស់ភាគីផ្សេងទៀត ព័ត៌មានទាំងអស់ដែលទាក់ទងទៅនឹងវិធានការចាំបាច់ដែលត្រូវបោះពុម្ពផ្សាយ ឬបង្កើតឡើងក្រោមអនុកថាខ័ណ្ឌ (ក) និង (ខ) អាចត្រូវបានទទួលជាបន្ទាន់ ។

(ឃ) ជូនដំណឹងដល់ភាគីផ្សេងទៀតតាមរយៈលេខាធិការដ្ឋានអាស៊ាន យ៉ាងហោចណាស់មួយឆ្នាំម្តងអំពីកិច្ចព្រមព្រៀង ឬការរៀបចំដែលទាក់ទងនឹងការវិនិយោគនាពេលអនាគតណាមួយ ដែលផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះ និងដែលខ្លួន គឺជាភាគីមួយនៃកិច្ចព្រមព្រៀងនេះ ។

២. គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានទាមទារអោយភាគីមួយផ្តល់ ឬបង្កលទ្ធភាពអោយទទួលបាននូវព័ត៌មានសម្ងាត់ណាមួយ ដែលការផ្សព្វផ្សាយព័ត៌មាននេះនឹងរាំងដល់ការ អនុវត្តច្បាប់ ឬផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ ឬដែលធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់របស់នីតិបុគ្គលជាក់លាក់ទាំងផ្នែកសាធារណៈ ឬឯកជន ។

៣. រាល់លិខិតជូនដំណឹង ឬលិខិតទំនាក់ទំនងទាំងអស់ ដែលធ្វើឡើងស្របតាមកថាខ័ណ្ឌទី១ ត្រូវធ្វើឡើងជាភាសាអង់គ្លេស ។

## មាត្រា ២០

## ការជំរុញការវិនិយោគ

ភាគីទាំងអស់ ត្រូវធ្វើសហប្រតិបត្តិការក្នុងការជំរុញ និងបង្កើនការយល់ដឹងទូលំទូលាយអំពីអាស៊ាន-ចិន ជាតំបន់វិនិយោគតាមរយៈ និងក្នុងចំណោមមធ្យោបាយផ្សេងទៀត :

(ក) បង្កើនការវិនិយោគរវាងអាស៊ាន-ចិន

(ខ) រៀបចំសកម្មភាពជំរុញការវិនិយោគ

(គ) ជំរុញការរៀបចំព្រឹត្តិការណ៍ប្រកួតប្រជែងផ្នែកធុរៈកិច្ច

(ឃ) រៀបចំ និងគាំទ្រដល់ការចាត់ចែងអោយមានការជួបសំណេះសំណាលពន្យល់ជាសង្ខេបផ្សេងៗ និងជាសិក្ខាសាលាស្តីពីកាលានុវត្តន៍ភាពវិនិយោគ និងស្តីពីច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយវិនិយោគ និង

(ង) ធ្វើការផ្លាស់ប្តូរព័ត៌មានអំពីបញ្ហាផ្សេងៗទៀត ដែលជាកង្វល់ទៅវិញទៅមកទាក់ទងទៅនឹងការជំរុញ និងការសម្របសម្រួលការវិនិយោគ

## មាត្រា ២១

## ការសម្របសម្រួលការវិនិយោគ

យោងតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន ភាគីទាំងអស់ត្រូវសហប្រតិបត្តិការ ដើម្បីសម្របសម្រួលការវិនិយោគ ក្នុងចំណោមអាស៊ាន និងចិន តាមរយៈ និងក្នុងចំណោមមធ្យោបាយផ្សេងទៀត :

(ក) បង្កើតឡើងនូវបរិស្ថានចាំបាច់សំរាប់គ្រប់ទម្រង់នៃការវិនិយោគ

(ខ) សំរួល និងធ្វើអោយកាន់តែសាមញ្ញនូវនិតិវិធីសំរាប់ការបំពេញបែបបទ និងការអនុម័តការវិនិយោគ

(គ) ជំរុញការផ្សព្វផ្សាយពត៌មានវិនិយោគ រាប់បញ្ចូលទាំងវិធាន បទប្បញ្ញត្តិ គោលនយោបាយ និងនីតិវិធីនៃការវិនិយោគ និង

(ឃ) បង្កើតនូវមជ្ឈមណ្ឌលវិនិយោគច្រកចេញ-ចូលតែមួយ នៅក្នុងប្រទេសភាគីម្ចាស់ផ្ទះនីមួយៗ ដើម្បីផ្តល់ការជួយជ្រោមជ្រែង និងសេវាពិគ្រោះយោបល់ដល់វិស័យអាជីវកម្ម រួមទាំងការសម្របសម្រួលចំពោះអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតសម្រាប់ប្រតិបត្តិការ ។

## មាត្រា ២២

## ការរៀបចំស្ថាប័ន

១. ការរង់ចាំការបង្កើតស្ថាប័នអចិន្ត្រៃយ៍មួយ គឺ AEM-MOFCOM ដែលគាំទ្រ និងជ្រោមជ្រែងដោយ SEOM-MOFCOM ត្រូវត្រួតពិនិត្យ គ្រប់គ្រង សម្របសម្រួល និងពិនិត្យមើលឡើងវិញនូវការអនុវត្តកិច្ចព្រមព្រៀងនេះ ។

២. លេខាធិការដ្ឋានអាស៊ាន ត្រូវធ្វើការត្រួតពិនិត្យ និងរាយការណ៍ជូន SEOM-MOFCOM អំពីការអនុវត្តកិច្ចព្រមព្រៀងនេះ ។ រាល់ភាគីទាំងអស់ត្រូវធ្វើសហប្រតិបត្តិការជាមួយលេខាធិការដ្ឋានអាស៊ាននៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។

៣. ភាគីនីមួយៗត្រូវតែងតាំងបុគ្គលទំនាក់ទំនង ដើម្បីសម្រួលដល់ទំនាក់ទំនងរវាងភាគីទាំងអស់ ស្តីពីបញ្ហាណាមួយ ដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ ។ នៅពេលមានការស្នើសុំពីសំណាក់ភាគីណាមួយ បុគ្គលទំនាក់ទំនងរបស់ភាគីដែលត្រូវបានស្នើសុំ ត្រូវកំណត់ការិយាល័យ ឬមន្ត្រីដែលទទួលខុសត្រូវចំពោះបញ្ហានោះ ហើយត្រូវជួយក្នុងការសម្របសម្រួលដល់ទំនាក់ទំនងជាមួយភាគីដែលធ្វើការស្នើសុំ ។

## មាត្រា ២៣

## ទំនាក់ទំនងជាមួយកិច្ចព្រមព្រៀងដទៃទៀត

គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវលើកលែងចេញពីសិទ្ធិ និងកាតព្វកិច្ចដែលមានស្រាប់របស់ភាគីណាមួយនៅក្រោមកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត ដែលខ្លួនជាភាគីមួយនៃកិច្ចព្រមព្រៀងអន្តរជាតិនោះឡើយ ។

## មាត្រា ២៤

## ការពិនិត្យឡើងវិញនូវ

AEM-MOFCOM ឬតំណាងដែលខ្លួនបានតែងតាំង ត្រូវជួបប្រជុំគ្នាក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទ នៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ហើយបន្ទាប់មកត្រូវជួបប្រជុំគ្នារៀងរាល់ពីរឆ្នាំម្តង ឬផ្សេងពីនេះ តាមការសមស្រប ក្នុងគោលបំណងពិនិត្យមើលឡើងវិញនូវកិច្ចព្រមព្រៀងនោះ ដើម្បីបន្ថែមគោលបំណងដែលមានចែង នៅក្នុងមាត្រា ២ (គោលបំណង) ។

## មាត្រា ២៥

## វិសោធនកម្ម

កិច្ចព្រមព្រៀងនេះអាចត្រូវបានធ្វើវិសោធនកម្មដោយមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីសំណាក់ភាគីទាំងអស់ ហើយវិសោធនកម្មនេះនឹងចូលជាធរមាន នៅកាលបរិច្ឆេទដែលអាចត្រូវបានព្រមព្រៀងដោយភាគីទាំងអស់ ។

## មាត្រា ២៦

## ការរក្សាទុក

សម្រាប់រដ្ឋសមាជិកអាស៊ាន កិច្ចព្រមព្រៀងនេះនឹងត្រូវបានរក្សាទុកជាមួយអគ្គលេខាធិការអាស៊ាន ដែលត្រូវផ្តល់សំណៅចម្លងដែលមានការបញ្ជាក់មួយច្បាប់នៃកិច្ចព្រមព្រៀងនេះភ្លាមៗដល់រដ្ឋសមាជិកអាស៊ាននីមួយៗ ។

## មាត្រា ២៧

## ការចូលជាធរមាន

១. កិច្ចព្រមព្រៀងនេះ នឹងចូលជាធរមានក្នុងរយៈពេលប្រាំមួយ (៦) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

២. ភាគីទាំងអស់សន្យាថា នឹងបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួនសម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ។

៣. នៅពេលដែលភាគីមួយមិនអាចបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួនសម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះក្នុងរយៈពេលប្រាំមួយ (៦) ខែ គិតចាប់ពីកាលបរិច្ឆេទចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនោះនៅក្រោមកិច្ចព្រមព្រៀងនេះ ត្រូវចាប់ផ្តើមក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងអំពីការបញ្ចប់នីតិវិធីផ្ទៃក្នុងនេះ ។

៤. ភាគីណាមួយត្រូវជូនដំណឹងដល់ភាគីដទៃទៀតទាំងអស់ជាលាយលក្ខណ៍អក្សរ នៅពេលបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួនសម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ។

**ដើម្បីជាសក្ខីភាព** ភាគីជាហត្ថលេខីទាំងអស់ដូចខាងក្រោម ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីវិនិយោគនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ។

ធ្វើនៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃឡង់ដ៍ នាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៩ ជាភាសាអង់គ្លេស ជាច្បាប់ចំលងចំនួន ០២ ច្បាប់ ។

| សំរាប់ ប្រទេសជាសមាជិកអាស៊ាន | សំរាប់ សាធារណរដ្ឋប្រជាមានិតចិន |
|---|---|
| *(ហត្ថលេខា)* | *(ហត្ថលេខា)* |
| **LIM JOCK SENG** | **CHEN DEMING** |
| រដ្ឋមន្ត្រីទី២ ក្រសួងការបរទេស និងពាណិជ្ជកម្ម | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម |

| | |
|---|---|
| **សំរាប់ ព្រះរាជាណាចក្រកម្ពុជា**<br><br>*(ហត្ថលេខា)*<br><br>**ចម ប្រសិទ្ធ**<br>ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | |
| **សំរាប់ សាធារណរដ្ឋឥណ្ឌូនេស៊ី**<br><br>*(ហត្ថលេខា)*<br><br>**MARI ELKA PANGESTU**<br>រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | |
| **សំរាប់ សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ**<br><br>*(ហត្ថលេខា)*<br><br>**NAM VIYAKETH**<br>រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម | |
| **សំរាប់ ម៉ាឡេស៊ី**<br><br>*(ហត្ថលេខា)*<br><br>**MUSTAPA MOHAMED**<br>រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មអន្តរជាតិ និងឧស្សាហកម្ម | |

| | |
|---|---|
| **សំរាប់ សហភាពមីយ៉ាន់ម៉ា**<br><br>*(ហត្ថលេខា)*<br><br>**U SOE THA**<br>រដ្ឋមន្ត្រីក្រសួងផែនការជាតិ និងអភិវឌ្ឍសេដ្ឋកិច្ច | |
| **សំរាប់ សាធារណរដ្ឋហ្វីលីពីន**<br><br>*(ហត្ថលេខា)*<br><br>**PETER B. FAVILA**<br>រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម | |
| **សំរាប់ សាធារណរដ្ឋសិង្ហបុរី**<br><br>*(ហត្ថលេខា)*<br><br>**LIM HNG KIANG**<br>រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម | |
| **សំរាប់ ព្រះរាជាណាចក្រថៃឡង់ដ៍**<br><br>*(ហត្ថលេខា)*<br><br>**PORNTIVA NAKASAI**<br>រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | |
| **សំរាប់ សាធារណរដ្ឋសង្គមនិយមវៀតណាម**<br><br>*(ហត្ថលេខា)*<br><br>**VU HUY HOANG**<br>រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម | |